# គោលការណ៍យ៉ក់យ៉ាកាំតា

## គោលការណ៍នៃការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិ ស្តីពី និន្នាការភេទ និង អត្តសញ្ញាណយេនឌ័រ


មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# គោលការណ៍យ៉កយ៉ាក៉ាតា

*គោលការណ៍នៃការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិ ស្តីពី*
*និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ*

“គោលការណ៍នេះត្រូវបានបង្កើតឡើង និងទទួលស្គាល់ដោយក្រុមអ្នកជំនាញអន្តរជាតិល្បីល្បាញផ្នែកសិទ្ធិមនុស្សអន្តរជាតិដែលបានជួបប្រជុំនៅក្នុងទីក្រុងយ៉កយ៉ាក៉ាតា ប្រទេសឥណ្ឌូនេស៊ី។ ការចេញផ្សាយជាភាសាខ្មែរនេះគឺជាការបកប្រែក្រៅផ្លូវការដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា”។

“These Principles are produced and adopted by a distinguished group of international human rights experts who met in Yogyakarta, Indonesia. This Khmer publication is an unofficial translation by the Cambodian Center for Human Rights”.

**មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា**
**Cambodian Center for Human Rights**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក.) គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និង មិនមាននិន្នាការនយោបាយ ដែលធ្វើការដើម្បីលើកកម្ពស់ និង ការពារលិទ្ធិប្រជាធិបតេយ្យ និង គោរពសិទ្ធិមនុស្សនៅព្រះរាជាណាចក្រកម្ពុជា។
Cambodian Center for Human Rights (CCHR) is an independent, non-aligned, non-governmental organization that works to promote and protect democracy and respect for human rights throughout the Kingdom of Cambodia.

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**
**មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា**

**អាសយដ្ឋាន** : ផ្ទះ ៧៩៨ ផ្លូវ៩៩ សង្កាត់បឹងត្របែក,
ខណ្ឌចំការមន ប្រអប់សំបុត្រ ២៥១៥ ភ្នំពេញ ប្រទេសកម្ពុជា
**លេខទូរស័ព្ទ ៖** (+ ៨៥៥) ២៣ ៧២៦ ៩០១
**លេខទូរសារ ៖** (+ ៨៥៥) ២៣ ៧២៦ ៩០២
**អ៊ីម៉ែល ៖** info@cchrcambodia.org
**គេហទំព័រ៖** http://www.cchrcambodia.org

**For more information, please contact:**
**Cambodian Center for Human Rights**

**Address :** #798, St.99, Boeng Trabek, Chamkarmon, P.O.Box: 2515, Phnom Penh, Cambodia
**Telephone :** (+855) 23 726 901
**Fax :** (+855) 23 726 902
**Email :** info@cchrcambodia.org
**Website:** http://www.cchrcambodia.org

# មាតិកា


មាតិកា ........ 1

លំនាំដើម អំពីគោលការណ៍យ៉កយ៉ាកាតា ........ 3

បុព្វកថា ........ 5

គោលការណ៍ ១ ៖ សិទ្ធិទទួលបានការប្រើប្រាស់ជាសកលនៃសិទ្ធិមនុស្ស ........ 7

គោលការណ៍ ២ ៖ សិទ្ធិទទួលបានសមភាព និងការមិនរើសអើង ........ 7

គោលការណ៍ ៣ ៖ សិទ្ធិទទួលបានការទទួលស្គាល់ចំពោះមុខច្បាប់ ........ 8

គោលការណ៍ទី ៤ ៖ សិទ្ធិរស់រានមានជីវិត ........ 9

គោលការណ៍ ៥ ៖ សិទ្ធិទទួលបានការការពារសុវត្ថិភាពបុគ្គល ........ 10

គោលការណ៍ ៦ ៖ សិទ្ធិទទួលបានឯកទត្តភាព ........ 11

គោលការណ៍ ៧ ៖ សិទ្ធិរួចផុតពីការដកហូតសេរីភាពដោយបំពាន ........ 12

គោលការណ៍ ៨ ៖ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ........ 12

គោលការណ៍ ៩ ៖ សិទ្ធិទទួលបានកិច្ចគាំពារប្រកបដោយមនុស្សធម៌ ក្នុងពេលជាប់ឃុំឃាំង ........ 13

គោលការណ៍ ១០ ៖ សិទ្ធិរួចផុតពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ........ 14

គោលការណ៍ ១១ ៖ សិទ្ធិទទួលបានកិច្ចការពារ ពីរាល់ទម្រង់នៃការកេងប្រវ័ញ្ច ការធ្វើអាជីវកម្ម និងការជួញដូរមនុស្ស ........ 15

គោលការណ៍ ១២ ៖ សិទ្ធិទទួលបានការងារធ្វើ ........ 15

គោលការណ៍ ១៣ ៖ សិទ្ធិទទួលបានសុវត្ថិភាពសង្គម និងវិធានការការពារសង្គមឯទៀត ........ 16

គោលការណ៍ ១៤ ៖ សិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ ........ 16

គោលការណ៍ ១៥ ៖ សិទ្ធិ ទទួលបានទីលំនៅគ្រប់គ្រាន់ ........ 17

គោលការណ៍ ១៦ ៖ សិទ្ធិទទួលបានការអប់រំ ........ 18

គោលការណ៍ ១៧ ៖ សិទ្ធិទទួលបានកម្រិតសុខភាពខ្ពស់បំផុត តាមដែលអាចធ្វើទៅបាន ........ 19

គោលការណ៍ ១៨ ៖ កិច្ចការពារពីការបំពានខាងវេជ្ជសាស្ត្រ ........ 20

គោលការណ៍ ១៩ ៖ សិទ្ធិសេរីភាពក្នុងការមានមតិ និងការសម្តែងមតិ ........ 21

គោលការណ៍ ២០ ៖ សិទ្ធិសេរីភាពក្នុងការប្រជុំ ឬក្នុងការចងក្រងគ្នាជាសមាគម ដោយសន្តិវិធី ........ 22

គោលការណ៍ ២១ ៖ សិទ្ធិសេរីភាពខាងការគិត សតិសម្បជញ្ញៈ និងសាសនា ........ 22

គោលការណ៍ ២២ ៖ សិទ្ធិធ្វើដំណើរ ........ 23

គោលការណ៍ ២៣ ៖ សិទ្ធិស្វែងរកកន្លែងជ្រកកោន....23
គោលការណ៍ ២៤ ៖ សិទ្ធិក្នុងការកសាងគ្រួសារ....24
គោលការណ៍ ២៥ ៖ សិទ្ធិចូលរួមក្នុងជីវភាពសាធារណៈ....25
គោលការណ៍ ២៦ ៖ សិទ្ធិចូលរួមក្នុងជីវភាពវប្បធម៌....25
គោលការណ៍ ២៧ ៖ សិទ្ធិក្នុងការលើកកម្ពស់សិទ្ធិមនុស្ស....26
គោលការណ៍ ២៨ ៖ សិទ្ធិទទួលបានមធ្យោបាយដោះស្រាយ និងសំណងដែលមានប្រសិទ្ធភាព....27
គោលការណ៍ ២៩ ៖ ទំនួលខុសត្រូវ....28
អនុសាសន៍បន្ថែម....29
ឧបសម្ព័ន្ធ....31

# សេចក្តីណែនាំ អំពីគោលការណ៍យ៉ុកយ៉ាកាតា

មនុស្សគ្រប់រូបកើតមក មានសេរីភាពនិងសមភាព ខាងសេចក្តីថ្លៃថ្នូរនិងសិទ្ធិ ។ សិទ្ធិមនុស្សមានលក្ខណៈជាសកល, អន្តរទំនាក់ទំនងគ្នា, ពឹងពាក់គ្នា, និងមិនអាចកាត់ផ្តាច់គ្នាបាន ។ និន្នាការភេទ[1] និងអត្តសញ្ញាណយេនឌ័រ [2] គឺជាផ្នែកមួយដ៏សំខាន់នៃសេចក្តីថ្លៃថ្នូរ និងភាពជាមនុស្សជាតិរបស់បុគ្គលនីមួយៗ ហើយមិនត្រូវយកប្រើជាមូលដ្ឋានរើសអើង ឬរំលោភបំពានសោះឡើយ ។

វឌ្ឍនភាពជាច្រើនត្រូវបានសម្រេចឡើង បំណងធានាឲ្យបានថា ពលរដ្ឋទាំងអស់នៃគ្រប់និន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ អាចរស់នៅជាមួយគ្នាបាន ប្រកបដោយសេចក្តីថ្លៃថ្នូរ និងក្តីគោរពស្មើៗគ្នាដែលបុគ្គលទាំងអស់មានសិទ្ធិទទួលបាន ។ បច្ចុប្បន្ននេះ បណ្តារដ្ឋជាច្រើនមានច្បាប់និងរដ្ឋធម្មនុញ្ញ ដែលធានាដល់សិទ្ធិស្មើភាពគ្នា និងគ្មានការរើសអើង ដោយមិនបែងចែកអំពីភេទ និន្នាការភេទ ឬក៏អត្តសញ្ញាណយេនឌ័រឡើយ ។

ទោះជាយ៉ាងនេះក្តី ការរំលោភសិទ្ធិមនុស្ស ដែលកើតមានចំពោះបុគ្គលទាំងឡាយ ដោយសារតែនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ បានបង្កឲ្យមានសញ្ញាណនៃក្តីព្រួយបារម្ភដ៏ជាក់ច្បាស់និងជាសកល ។ ការរំលោភសិទ្ធិមនុស្សទាំងនេះ រួមមាន ៖ ការសម្លាប់, ទារុណកម្ម និងការធ្វើបាប, ការបៀតបៀនផ្លូវភេទ និងការចាប់រំលោភ, ការឈ្លានពានឯកទត្តភាព, ការឃុំឃាំងដោយបំពាន, ការបដិសេធផ្តល់ឱកាសការងារ និងការសិក្សា, និងការរើសអើងធ្ងន់ធ្ងរពាក់ព័ន្ធនឹងការប្រើប្រាស់សិទ្ធិមនុស្សផ្សេងទៀត ។ ជាញឹកញយ ការរំលោភសិទ្ធិមនុស្សទាំងនេះ កើតមានកាន់តែធ្ងន់ធ្ងរថែមទៀត ដោយសារបទពិសោធន៍នៃការឆ្លងប្រើទម្រង់អំពើហិង្សាផ្សេងទៀត, ការស្អប់ខ្ពើម, ការរើសអើង, និងការមិនរាប់រក ពីហេតុនៃកត្តាជាតិសាសន៍ អាយុ សាសនា ពិការភាព ឬក៏ស្ថានភាពសេដ្ឋកិច្ច សង្គម ឬស្ថានភាពផ្សេងទៀត ។

បណ្តារដ្ឋនិងសង្គមជាច្រើន បានដាក់បន្ទុកបទដ្ឋាននិន្នាការភេទនិងយេនឌ័រ លើបុគ្គលម្នាក់ៗ តាមរយៈប្រពៃណី ច្បាប់ និងអំពើហិង្សា ហើយព្យាយាមត្រួតពិនិត្យ ពីរបៀបរបបដែលបុគ្គលទាំងនោះដកពិសោធន៍ចំពោះទំនាក់ទំនងផ្ទាល់ខ្លួន និងពីរបៀបរបបដែលពួកគេកំណត់អត្តសញ្ញាណរបស់ខ្លួន ។ ការដាក់ចេញជាគោលការណ៍លើនិន្នាការភេទ បន្តជាកត្តាចម្បងនៅពីក្រោយអំពើហិង្សាលើយេនឌ័រ និងវិសមភាពយេនឌ័រ ។

ប្រព័ន្ធអន្តរជាតិបានបោះជំហានប្រសើរយ៉ាងច្រើន លើសមភាពយេនឌ័រ និងកិច្ចការពារប្រឆាំងនឹងអំពើហិង្សាក្នុងសង្គម សហគមន៍ និងក្នុងគ្រួសារ ។ បន្ថែមលើសនេះ យន្តការសិទ្ធិមនុស្សសំខាន់ៗរបស់អង្គការសហប្រជាជាតិ បានបញ្ជាក់ពីកាតព្វកិច្ចរបស់រដ្ឋភាគី ក្នុងការធានាឲ្យបាននូវកិច្ចការពារដ៏មានប្រសិទ្ធភាព ដល់បុគ្គលទាំងឡាយ ពីការរើសអើងដោយសារនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ។ ទោះជាយ៉ាងនេះក្តី ការឆ្លើយតបពីសំណាក់អន្តរជាតិចំពោះការបំពានសិទ្ធិមនុស្ស ពីហេតុនៃនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ នៅមានលក្ខណៈបែកខ្ញែក និងគ្មានសង្គតិភាពនឹងគ្នានៅឡើយ ។

---

[1] និន្នាការភេទ បានដល់សមត្ថភាពរបស់បុគ្គលម្នាក់ៗ ក្នុងការសម្តែងអារម្មណ៍ ភាពរំជើបរំជួល និងចំណាប់អារម្មណ៍ផ្លូវភេទ ចំពោះទំនាក់ទំនងផ្លូវភេទ ជាមួយបុគ្គលឯទៀត ដែលមានយេនឌ័រខុសគ្នាឬដូចគ្នា ឬដែលមានយេនឌ័រច្រើនប្រភេទ ។

[2] អត្តសញ្ញាណយេនឌ័រ បានដល់បទពិសោធន៍ខាងក្នុងនិងផ្ទាល់ខ្លួន ដែលមានលក្ខណៈស៊ីជម្រៅរបស់បុគ្គលម្នាក់ៗ ដែលអាចឬមិនអាចឆ្លុះបញ្ចាំងពីភេទដែលខ្លួនមានមកពីកំណើត ដោយរាប់ទាំងរូបរាងខាងក្រៅ (ដែលអាចទាក់ទងនឹងការជ្រើសរើសដោយខ្លួនឯងផ្ទាល់ ក្នុងការផ្លាស់ប្តូររូបរាងកាយ តាមរយៈវិធីវេជ្ជសាស្ត្រ ការវះកាត់ ឬវិធីផ្សេងៗទៀត) និងការសម្តែងផ្សេងទៀត អំពីលក្ខណៈយេនឌ័ររបស់ខ្លួន តាមរយៈសម្លៀកបំពាក់ ពាក្យសម្តី និងចរិតលក្ខណៈ ។

ដើម្បីដោះស្រាយបញ្ហាទាំងនេះ ជាការចាំបាច់ណាស់ ដែលទាមទារឲ្យមានការយល់ដឹងប្រកបដោយសង្គតិភាព អំពីរបបច្បាប់សិទ្ធិមនុស្ស និងការអនុវត្តរបស់វាទៅលើបញ្ហានិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ។ ការណ៍នេះទាមទារនូវការចងក្រង និងបញ្ជាក់ឲ្យច្បាស់លាស់ ពីកាតព្វកិច្ចរដ្ឋចំពោះច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលមានស្រាប់ ដើម្បីលើកស្ទួយ និងការពារដល់បុគ្គលគ្រប់រូប ឲ្យទទួលបានសិទ្ធិមនុស្សស្មើៗគ្នា និងដោយមិនរើសអើង ។

«គណៈកម្មាការចៅក្រមអន្តរជាតិ» និង«សេវាកម្មអន្តរជាតិសម្រាប់សិទ្ធិមនុស្ស» ដែលដើរតួក្នុងនាមសម្ព័ន្ធអង្គការសិទ្ធិមនុស្សនានា បាននិងកំពុងធ្វើគម្រោងមួយ ដើម្បីបង្កើតគោលការណ៍ច្បាប់អន្តរជាតិស្តីពីការអនុវត្តច្បាប់អន្តរជាតិ ចំពោះការបំពានសិទ្ធិពីហេតុនៃនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ សំដៅធ្វើយ៉ាងណាឲ្យកាតព្វកិច្ចសិទ្ធិមនុស្សរបស់រដ្ឋភាគី កាន់តែមានភាពច្បាស់លាស់ និងសង្គតិភាពប្រសើរឡើង ។

អ្នកជំនាញការសិទ្ធិមនុស្សដ៏ចំណានមួយក្រុម បានធ្វើសេចក្តីព្រាង តាក់តែង ពិភាក្សា និងសម្រាំងគោលការណ៍នេះ ។ បន្ទាប់ពីកិច្ចប្រជុំអ្នកជំនាញការមួយ ប្រព្រឹត្តិឡើងនៅសាកលវិទ្យាល័យហ្គាជ្យាហ៍ម៉ាដា(Gadjah Mada) នៃទីក្រុងយ៉កយ៉ាក៉ាតារបស់ប្រទេសឥណ្ឌូនេស៊ី កាលពីថ្ងៃទី៦ដល់ទី៩ ខែវិច្ឆិកា ឆ្នាំ២០០៦ រួចមក អ្នកជំនាញការល្បីឈ្មោះចំនួន ២៩ រូប មកពី ២៥ ប្រទេស ដែលមានប្រវត្តិនិងឯកទេស ពាក់ព័ន្ធនឹងវិស័យច្បាប់សិទ្ធិមនុស្ស បានអនុម័តលើគោលការណ៍យ៉កយ៉ាក៉ាតា ស្តីពីការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិ ចំពោះនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ។

អ្នករាយការណ៍នៃកិច្ចប្រជុំនេះ គឺលោកសាស្ត្រាចារ្យ មាយខឹល អូហ្វលាទី (Michael O'Flaherty) បានធ្វើវិភាគទានយ៉ាងសម្បើមទៅលើសេចក្តីព្រាង និងការកែសម្រួលនៃគោលការណ៍នេះ ។ ការប្តេជ្ញាចិត្ត និងកិច្ចខំប្រឹងប្រែងដោយមិនខ្លាចនឿយហត់របស់លោក បានផ្តល់ជាលទ្ធផលលើដំណើរការនេះប្រកបដោយជោគជ័យ ។

គោលការណ៍យ៉កយ៉ាក៉ាតា បានឆ្លើយតបនឹងបទដ្ឋានសិទ្ធិមនុស្សជាច្រើន និងការអនុវត្តនានាពាក់ព័ន្ធនឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ។ គោលការណ៍នេះ បញ្ជាក់នូវកាតព្វកិច្ចចម្បងរបស់រដ្ឋ ក្នុងកិច្ចការពារសិទ្ធិមនុស្ស ។ គោលការណ៍នីមួយៗ មានភ្ជាប់អនុសាសន៍លម្អិតសម្រាប់រដ្ឋ ។ អ្នកឯកទេសក៏បញ្ជាក់ថា ទោះជាយ៉ាងណាក្តី ការលើកកម្ពស់និងកិច្ចការពារសិទ្ធិមនុស្ស គឺជាកាតព្វកិច្ចរបស់យើងទាំងអស់គ្នា ។ អនុសាសន៍បន្ថែមក៏មានដាក់ជូនដល់តួអង្គដទៃទៀត ជាអាទិ៍ ប្រព័ន្ធសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ ប្រព័ន្ធផ្សព្វផ្សាយ អង្គការក្រៅរដ្ឋាភិបាល និងម្ចាស់ជំនួយ ផងដែរ ។

អ្នកឯកទេសបានមូលមតិគ្នាថា គោលការណ៍យ៉កយ៉ាក៉ាតាឆ្លុះបញ្ចាំងស្ថានភាពច្បាប់សិទ្ធិមនុស្សអន្តរជាតិពាក់ព័ន្ធនឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ។ ពួកគាត់ក៏ទទួលស្គាល់ថា រដ្ឋនឹងអាចមានកាតព្វកិច្ចផ្សេងទៀត ខណៈដែលច្បាប់សិទ្ធិមនុស្សនឹងបន្តវិវឌ្ឍន៍ ។

គោលការណ៍យ៉កយ៉ាក៉ាតា បញ្ជាក់ពីការចងភ្ជាប់ជាមួយបទដ្ឋានច្បាប់អន្តរជាតិ ដែលរដ្ឋទាំងអស់ចាំបាច់ត្រូវគោរពតាម ។ ពួកគាត់សន្យាឲ្យមានអនាគតផ្សេងមួយ ដែលខណៈនោះមនុស្សទាំងអស់គ្នាកើតមកទទួលបានសេរីភាពនិងភាពស្មើគ្នា ក្នុងសេចក្តីថ្លៃថ្នូរនិងសិទ្ធិ ដែលត្រូវបានកំណត់តាំងពីពេលចាប់កំណើត ។

| | |
|---|---|
| **សូនា អូណ្ឌ្រហ្វី ក័រវៀ** | **វិទីត មូនតាប៊ិន** |
| សហប្រធាន | សហប្រធាន |

*យើងខ្ញុំ ជាគណៈអន្តរជាតិឯកទេសខាងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ស្តីពី និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ*

## បុព្វកថា

**បញ្ជាក់ឡើងវិញថា** មនុស្សគ្រប់រូបកើតមក មានសេរីភាពនិងសមភាព ខាងសេចក្តីថ្លៃថ្នូរនិងសិទ្ធិ ហើយថាមនុស្សគ្រប់រូប មានសិទ្ធិប្រើប្រាស់សិទ្ធិរបស់ខ្លួន ដោយគ្មានការបែងចែកតាមគ្រប់ទម្រង់ទាំងអស់ ដូចជា ៖ ជាតិសាសន៍, ពណ៌សំបុរ, ភេទ, ភាសា, សាសនា, ទស្សនៈនយោបាយឬទស្សនៈផ្សេងៗ, ដើមកំណើតប្រទេសឬសង្គម, ទ្រព្យសម្បត្តិ, កំណើត, ឬស្ថានភាពដទៃទៀត ។

**រងការរំខាន** ដោយអំពើហិង្សា ការបៀតបៀន ការរើសអើង ការបដិសេធមិនរាប់រក ការម៉ាក់ងាយ និងបុរេនិច្ឆ័យប្រឆាំងលើបុគ្គលនៃគ្រប់តំបន់ក្នុងពិភពលោក ពីហេតុនៃនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័ររបស់ពួកគេ ហើយបទពិសោធន៍ទាំងនេះ ត្រូវបានរាប់បញ្ចូលមានការរើសអើង ដោយសារ យេនឌ័រ ជាតិសាសន៍ អាយុ សាសនា ពិការភាព សុខភាព និងស្ថានភាពសេដ្ឋកិច្ច ហើយរាល់ទម្រង់នៃអំពើហិង្សា ការបៀតបៀន ការរើសអើង ការបដិសេធមិនរាប់រក ការម៉ាក់ងាយ និងបុរេនិច្ឆ័យនេះ បណ្តាលឲ្យសុចរិតភាព និងសេចក្តីថ្លៃថ្នូររបស់អ្នកទាំងនេះ ត្រូវបានរងនូវការរំលោភបំពាន ហើយអាចធ្វើឲ្យធ្លាក់ចុះនៃការឲ្យតម្លៃខ្លួនឯង និងការចូលរួមក្នុងសង្គម ហើយការណ៍នេះអាចនឹងនាំឲ្យមានការបិតបាំង ឬរងនូវសម្ពាធក្នុងការបង្ហាញអត្តសញ្ញាណរបស់បុគ្គលម្នាក់ៗ ហើយធ្វើឲ្យពួកគាត់រស់នៅដោយភាពភ័យខ្លាច និងមិនចេញមុខ ។

**ដោយដឹងថា** តាមប្រវត្តិសាស្ត្រ មនុស្សជាច្រើនទទួលរងការរំលោភបំពានសិទ្ធិមនុស្ស ដោយបុព្វហេតុពួកគាត់ជាឬត្រូវបានគេយល់ថាជាមនុស្សស្រីស្រលាញ់ស្រី ឬមនុស្សប្រុសស្រលាញ់ប្រុស ឬមនុស្សស្រលាញ់ស្រីផងប្រុសផង និងដោយសារការបង្ហាញពីនិន្នាការភេទ ឬការផ្លាស់ប្តូរភេទ ឬការចូលរួមក្នុងសង្គមមនុស្សណាមួយដែលបង្ហាញពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ របស់ពួកគាត់ ។

**យល់ថា** អត្តសញ្ញាណយេនឌ័រ សំដៅលើបទពិសោធន៍ជាអារម្មណ៍រំជួលចិត្តខ្លាំងផ្ទៃកខាងក្នុង របស់បុគ្គលម្នាក់ៗពាក់ព័ន្ធនឹងយេនឌ័រ ដែលអាចឬមិនអាចឆ្លើយតបនឹងភេទ ដែលមានមកពីកំណើត ដោយរួមបញ្ចូលទាំងអារម្មណ៍ផ្ទៃករាងកាយផ្ទាល់ខ្លួន (ដែលអាចពាក់ព័ន្ធនឹងការផ្លាស់ប្តូររូបរាងកាយ ឬមុខងាររាងកាយណាមួយ តាមរយៈវេជ្ជសាស្ត្រ ការវះកាត់ ឬមធ្យោបាយនានា) ព្រមទាំងការសម្តែងផ្សេងទៀត អំពីយេនឌ័ររបស់ខ្លួន តាមរយៈសម្លៀកបំពាក់ ពាក្យសម្តី និងអត្តចរិត ។

**តាមការអង្កេតឃើញថា** ច្បាប់សិទ្ធិមនុស្សអន្តរជាតិអះអាងថាមនុស្សគ្រប់រូបមិនថាមាននិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រណាមួយនោះទេ គឺអាចប្រើប្រាស់សិទ្ធិមនុស្សរបស់ខ្លួនពេញលេញ ហើយរាល់ការអនុវត្តនូវការទទួលបានសិទ្ធិមនុស្សនេះ គួរពិចារណាពីស្ថានភាពពិសេស និងបទពិសោធន៍របស់មនុស្សដែលមាននិន្នាការភេទ និងយេនឌ័រផ្សេងៗ ហើយរាល់វិធានការនានា ត្រូវយកចិត្តទុកដាក់ដល់ផលប្រយោជន៍កុមារ ហើយកុមារទាំងឡាយដែលអាចមានទស្សនយោបល់ផ្ទាល់ខ្លួន គួរមានសិទ្ធិក្នុងការសម្តែងទស្សនៈរបស់ខ្លួនដោយសេរី ហើយទស្សនៈទាំងនេះ នឹងត្រូវថ្លឹងថ្លែងនឹងអាយុ ភាពចាស់ទុំរបស់កុមារទាំងនេះ ។

**កត់សម្គាល់ថា** ច្បាប់សិទ្ធិមនុស្សអន្តរជាតិបានដាក់បញ្ចូលនូវបម្រាមទាំងស្រុង លើរាល់ទម្រង់នៃការរើសអើង ក្នុងការទទួលបាននូវសិទ្ធិមនុស្ស សិទ្ធិពលរដ្ឋ វប្បធម៌ សេដ្ឋកិច្ច នយោបាយ និងសង្គមកិច្ច ដោយពេញលេញ ហើយការគោរពដល់និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រគឺមានសារៈសំខាន់ សម្រាប់ការទទួលបាននូវភាពស្មើរគ្នា រវាងបុរសនិងស្ត្រី ហើយរដ្ឋត្រូវចាត់វិធានការក្នុងការឈានទៅរកការលុបបំបាត់គំនិតបុរេនិច្ឆ័យ និងប្រពៃណីដែលផ្តោតលើទស្សនៈទាបខ្ពស់រវាងបុគ្គលម្នាក់ៗ ដោយសារបុព្វហេតុភេទ ឬតួនាទីដែលត្រូវបានគេរើសអើង រវាងបុរសនិងស្ត្រី ហើយក៏កត់សម្គាល់ឃើញថា សហគមន៍អន្តរជាតិបានទទួលស្គាល់សិទ្ធិរបស់បុគ្គលម្នាក់ៗ ក្នុងការសម្រេចចិត្តដោយសេរី និងដោយទំនួលខុសត្រូវលើបញ្ហាផ្លូវភេទ ដោយរួមទាំងសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ដោយមិនរងការបង្ខំ ការរើសអើង និងហិង្សានោះឡើយ ។

**ទទួលស្គាល់ថា** ការណ៍ដែលអាចដាក់ចេញនូវវិធានការនានានៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ គឺមានគុណតម្លៃយ៉ាងសំខាន់ ហើយត្រូវតែឆ្លុះបញ្ចាំងដល់ជីវភាព និងបទពិសោធន៍នានារបស់បុគ្គល ដែលមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ។

**ទទួលយល់ថា** ការណ៍ដាក់ចេញនូវវិធានការនានានេះ គឺអាស្រ័យលើស្ថានភាព បច្ចុប្បន្ននៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ ហើយនឹងតម្រូវឲ្យមានការកែសម្រួលជាដរាប ដើម្បីដាក់បញ្ចូលនូវវិវឌ្ឍន៍នានានៃច្បាប់ និងការអនុវត្តដល់ជីវភាព និងបទពិសោធន៍ជាក់លាក់ របស់បុគ្គលដែលមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រផ្សេងៗ តាមកាលៈទេសៈ និងតំបន់ និងប្រទេសនានា ។

ស្រង់ចេញពីកិច្ចប្រជុំអ្នកឯកទេសដែល

ប្រារព្ធនៅទីក្រុងយ៉កយ៉ាកាតា ប្រទេសឥណ្ឌូនេស៊ី

នៅថ្ងៃទី៦ដល់៩ ខែវិច្ឆិកា ឆ្នាំ២០០៦

ដែលសម្រេចអនុម័តលើគោលការណ៍ នេះ ៖

## គោលការណ៍ ១ ៖ សិទ្ធិទទួលបានការប្រើប្រាស់ជាសកលនៃសិទ្ធិមនុស្ស

មនុស្សគ្រប់រូបកើតមក មានសេរីភាពនិងសមភាព ខាងសេចក្តីថ្លៃថ្នូរនិងសិទ្ធិ ។ មនុស្សទាំងឡាយនៃគ្រប់និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ អាចប្រើប្រាស់សិទ្ធិមនុស្សទាំងអស់របស់ខ្លួន បានយ៉ាងពេញលេញ ។

**រដ្ឋមានកាតព្វកិច្ចត្រូវ ៖**

ក. បញ្ចូលគោលការណ៍សិទ្ធិមនុស្ស ដែលមានលក្ខណៈ ៖ ជាសកល, អន្តរទំនាក់ទំនងគ្នា, ពឹងពាក់គ្នា, និងមិនអាចកាត់ផ្តាច់គ្នាបាន ទៅក្នុងរដ្ឋធម្មនុញ្ញ ឬច្បាប់សមស្របផ្សេងទៀតរបស់ខ្លួន ហើយធានាឲ្យបាននូវការប្រើប្រាស់ជាសកលនៃសិទ្ធិមនុស្ស

ខ. ធ្វើវិសោធនកម្មច្បាប់នានា រាប់ទាំងច្បាប់ឧក្រិដ្ឋ ដើម្បីធានាឲ្យបាននូវសង្គតិភាព ក្នុងការប្រើប្រាស់ជាសកលនៃសិទ្ធិមនុស្ស

គ. បង្កើតកម្មវិធីអប់រំ និងផ្សព្វផ្សាយ ដើម្បីលើកកម្ពស់និងពង្រឹងដល់បុគ្គលគ្រប់រូប ដោយមិនប្រកាន់ពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ឲ្យចេះប្រើប្រាស់សិទ្ធិមនុស្សទាំងអស់របស់ខ្លួន បានយ៉ាងពេញលេញ

ឃ. ធ្វើសមាហរណកម្មទៅក្នុងគោលនយោបាយ និងការធ្វើការសម្រេចចិត្តរបស់រដ្ឋ នូវគោលគំនិតពហុនិយម ដែលទទួលស្គាល់និងធានា ដល់លក្ខណៈអន្តរទំនាក់ទំនងគ្នា និងលក្ខណៈមិនអាចកាត់ផ្តាច់គ្នាបាន នៃរាល់ទិដ្ឋភាពអត្តសញ្ញាណមនុស្សទាំងអស់ រួមទាំងនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រផងដែរ ។

## គោលការណ៍ ២ ៖ សិទ្ធិទទួលបានសមភាព និងការមិនរើសអើង

ជនគ្រប់រូប អាចប្រើប្រាស់សិទ្ធិមនុស្សទាំងអស់បាន ដោយមិនរើសអើងពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ។ ជនគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងទទួលបានកិច្ចគាំពារពីច្បាប់ស្មើៗគ្នា ដោយពុំមានការរើសអើងដូចពោលមកឡើយ មិនថាវាប៉ះពាល់ដល់ការប្រើប្រាស់សិទ្ធិមនុស្សដទៃទៀត ឬយ៉ាងណានោះទេ ។ ច្បាប់ត្រូវហាមឃាត់រាល់ទម្រង់នៃការរើសអើងរបៀបនេះ ហើយត្រូវធានាថា មនុស្សគ្រប់រូបទទួលបានកិច្ចគាំពារដោយស្មើភាព និងប្រសិទ្ធភាព ប្រឆាំងនឹងការរើសអើងរបៀបនេះ ។

ការរើសអើងដែលឈរលើមូលដ្ឋាន នៃនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ រួមមាន ៖ ការបង្ហាញអំពីភាពខុសគ្នា, ការមិនរាប់បញ្ចូល, ការកម្រិត, ឬការលម្អៀងទាំងឡាយណា ដោយផ្អែកលើមូលដ្ឋាន នៃនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ដែលមានគោលបំណងឬដះឥទ្ធិពល ធ្វើឲ្យលុបបាត់ឬខូចខាតដល់ ៖ សមភាពចំពោះមុខច្បាប់ ឬកិច្ចគាំពារស្មើៗគ្នាពីច្បាប់, ការទទួលស្គាល់, ការទទួលបាន ឬការប្រើប្រាស់ដែលឈរលើមូលដ្ឋានស្មើភាពនៃសិទ្ធិមនុស្សទាំងអស់ និងសេរីភាពមូលដ្ឋាននានា ។ ការរើសអើងដែលផ្អែកលើនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ជាទូទៅ អាចរាប់បញ្ចូលទាំងការរើសអើងដែលមានមូលដ្ឋានផ្សេងទៀត ជាអាទិ៍ ៖ យេនឌ័រ, ពូជសាសន៍, អាយុ, សាសនា, ពិការភាព, សុខភាព, និងស្ថានភាពសេដ្ឋកិច្ច ។

**រដ្ឋមានកាតព្វកិច្ចត្រូវ ៖**

ក. ដាក់បញ្ចូលគោលការណ៍សមភាព និងការមិនរើសអើង ដែលឈរលើមូលដ្ឋាននៃនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ទៅក្នុងរដ្ឋធម្មនុញ្ញ ឬច្បាប់សមស្របផ្សេងទៀតរបស់ខ្លួន ប្រសិនណាមិនទាន់បានដាក់បញ្ចូលទេនោះ ដែលអាចធ្វើឡើងតាមរយៈវិសោធនកម្ម និងបំណកស្រាយ ហើយត្រូវធានាសម្រេចឲ្យបាននូវគោលការណ៍នេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់

ខ. លុបចោលបញ្ញត្តិឧក្រិដ្ឋ និងបញ្ញត្តិច្បាប់ផ្សេងទៀត ដែលហាមឃាត់ ឬដែលដាក់កំហិត លើសកម្មភាពផ្លូវភេទ ក្នុងចំណោមមនុស្សភេទដូចគ្នាដែលគ្រប់អាយុដូចបានកំណត់ ហើយធានាថាអាយុអនុញ្ញាតឲ្យប្រព្រឹត្តសកម្មភាពផ្លូវភេទ ត្រូវបានកំណត់ស្មើគ្នាចំពោះមនុស្ស ទាំងភេទដូចគ្នា និងភេទខុសគ្នា

គ. ចាត់វិធានការខាងនីតិបញ្ញត្តិ និងវិធានការសមស្របផ្សេងទៀត ដើម្បីហាមឃាត់និងលុបបំបាត់ ការរើសអើងខាងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ក្នុងវង្វង់បុគ្គល និងសាធារណជន

ឃ. ចាត់វិធានការសមស្របនានា ដើម្បីធានាឲ្យមានវឌ្ឍនភាពគ្រប់គ្រាន់ ចំពោះបុគ្គលទាំងឡាយ ដែលមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រចម្រុះបែប ពីព្រោះវាជាកត្តាចាំបាច់ ដើម្បីធានាថា ក្រុមឬបុគ្គលទាំងនេះ អាចប្រើប្រាស់ឬអនុវត្តសិទ្ធិមនុស្ស បានដោយស្មើភាព ។ វិធានការទាំងនេះមិនត្រូវចាត់ទុកថាជាការរើសអើងនោះទេ

ង. ដើម្បីប្រតិកម្មតបនឹងការរើសអើង ខាងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ពិចារណាលើឥរិយាបថទាំងឡាយណា ដែលការរើសអើងបែបនេះ អាចពាក់ព័ន្ធនឹងការរើសអើងបែបផ្សេងទៀត

ច. ចាត់វិធានការសមស្របទាំងអស់ រាប់ទាំងកម្មវិធីសិក្សា និងវគ្គបណ្តុះបណ្តាល បំណងសម្រេចឲ្យបាននូវការលុបបំបាត់អាកប្បកិរិយា ឬឥរិយាបថរើសអើងឬអន្តរាយទាំងឡាយ ដែលទាក់ទងនឹងគំនិតបែងចែកទាបខ្ពស់ ដល់និន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ឬការបង្ហាញលក្ខណៈយេនឌ័រ ឯណានីមួយនោះ ។

## គោលការណ៍ ៣ ៖ សិទ្ធិទទួលបានការទទួលស្គាល់ចំពោះមុខច្បាប់

បុគ្គលគ្រប់រូប មានសិទ្ធិឲ្យគេទទួលស្គាល់នៅគ្រប់ទីកន្លែង ថាជាមនុស្សចំពោះមុខច្បាប់ ។ បុគ្គលដែលមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រខុសពីគេ មានសិទ្ធិស្របច្បាប់ នៅគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិត ។ និន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់បុគ្គលម្នាក់ៗ មានសារៈសំខាន់ សម្រាប់បុគ្គលិកលក្ខណៈរបស់បុគ្គលនីមួយៗ ហើយក៏ជាទិដ្ឋភាពមូលដ្ឋាននៃការតាំងចិត្តផ្ទាល់ខ្លួន សេចក្តីថ្លៃថ្នូរ និងសេរីភាព ។ គ្មានជនណាម្នាក់ត្រូវបានបង្ខំឲ្យទទួលការព្យាបាលផ្នែកវេជ្ជសាស្ត្រ រួមទាំងការវះកាត់ប្តូរភេទ ការព្យាបាលមិនឲ្យមានកូន ឬការព្យាបាលអ័រម៉ូន ដើម្បីទទួលបាននូវការទទួលស្គាល់ស្របច្បាប់ ចំពោះអត្តសញ្ញាណយេនឌ័រ នោះទេ ។ គ្មានស្ថានភាព ដូចជាអាពាហ៍ពិពាហ៍ ឬភាពជាឪពុកម្តាយ ត្រូវបានគេស្នើឡើង ជាលក្ខខណ្ឌរារាំងការទទួលស្គាល់ស្របច្បាប់ នៃអត្តសញ្ញាណយេនឌ័ររបស់បុគ្គលណាមួយឡើយ ។ គ្មានជនណាម្នាក់ត្រូវបានរងសម្ពាធឲ្យលាក់បាំង រងការទប់ស្កាត់ឬបដិសេធអំពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័ររបស់បុគ្គលនោះទេ ។

**រដ្ឋមានកាតព្វកិច្ចត្រូវ៖**

ក. ធានាថាបុគ្គលគ្រប់រូប ត្រូវបានផ្តល់សិទ្ធិស្របច្បាប់ ចំពោះបញ្ហាស៊ីវិល ដោយគ្មានការរើសអើងលើនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ហើយត្រូវបានផ្តល់ឱកាសប្រើប្រាស់សិទ្ធិទាំងនេះ រួមទាំងសិទ្ធិស្មើគ្នាក្នុងការចុះកិច្ចសន្យា និងក្នុងការគ្រប់គ្រង ការធ្វើជាម្ចាស់កម្មសិទ្ធិ ការទទួលបាន (រួមទាំងការទទួលបានកេរមរតក) ការរៀបចំចាត់ចែង ការប្រើប្រាស់ និងការរំលាយទ្រព្យសម្បត្តិនានា

ខ. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីគោរព និងទទួលស្គាល់ឲ្យបានពេញលេញ នូវសិទ្ធិស្របច្បាប់ ក្នុងការទទួលបានការទទួលស្គាល់អត្តសញ្ញាណយេនឌ័រ ដោយផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ

គ. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាឲ្យបានថា នីតិវិធីដែលរដ្ឋចេញលិខិតស្នាមបញ្ជាក់អំពីភេទ/យេនឌ័ររបស់បុគ្គលនីមួយៗ រួមមាន សំបុត្រកំណើត, លិខិតឆ្លងដែន, ឯកសារបោះឆ្នោត, និងឯកសារផ្សេងទៀត ពិតជាឆ្លុះបញ្ចាំងពីអត្តសញ្ញាណយេនឌ័រ ដែលត្រូវបានកំណត់ដោយសាមីខ្លួននោះផ្ទាល់

ឃ. ធានាថានីតិវិធីទាំងនោះ មានប្រសិទ្ធផល សុក្រិតភាព និងគ្មានការរើសអើង ព្រមទាំងគោរពនូវភាពថ្លៃថ្នូរ និងឯកទត្តភាពដល់បុគ្គលដែលពាក់ព័ន្ធ

ង. ធានាថារាល់ការកែប្រែឯកសារបញ្ជាក់អត្តសញ្ញាណ នឹងត្រូវបានទទួលស្គាល់ ក្នុងគ្រប់បរិបទទាំងអស់ នៅពេលដែលច្បាប់ឬគោលនយោបាយនានា តម្រូវឲ្យមានការបញ្ជាក់ ឬវែកញែកអំពីយេនឌ័ររបស់បុគ្គល

ច. អនុវត្តកម្មវិធីផ្សេងៗ ដែលមានគោលដៅផ្តល់ការគាំទ្រផ្នែកសង្គមកិច្ច ដល់ជនទាំងឡាយណាដែលធ្លាប់ឆ្លងកាត់ដំណាក់កាលផ្លាស់ប្តូរ ឬបន្លាស់ប្តូរភេទ ។

## គោលការណ៍ទី ៤៖ សិទ្ធិរស់រានមានជីវិត

បុគ្គលគ្រប់រូបមានសិទ្ធិរស់រានមានជីវិត ។ គ្មានបុគ្គលណាមួយ អាចបំពានយកជីវិតនរណាម្នាក់បានឡើយ នេះរាប់ទាំងការសម្អាងលើការពិចារណាអំពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ។ ការដាក់ទោសប្រហារជីវិតមិនត្រូវធ្វើឡើង ដោយឈរលើមូលដ្ឋានទាក់ទងនឹងសកម្មភាពផ្លូវភេទ ដែលត្រូវបានព្រមព្រៀងប្រព្រឹត្តដោយបុគ្គលដែលគ្រប់អាយុអនុញ្ញាត ឬលើមូលដ្ឋានទាក់ទងនឹងនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ នោះឡើយ ។

**រដ្ឋមានកាតព្វកិច្ចត្រូវ៖**

ក. លុបចោលរាល់ទម្រង់ទាំងអស់នៃបទឧក្រិដ្ឋ ដែលមានគោលបំណង ឬឥទ្ធិពលហាមឃាត់សកម្មភាពផ្លូវភេទព្រមព្រៀងប្រព្រឹត្តិដោយបុគ្គលគ្រប់អាយុ ហើយដរាបណាបញ្ញត្តិនេះនៅជាធរមាន មិនត្រូវដាក់ទោសប្រហារជីវិត ចំពោះបុគ្គលដែលត្រូវបានកាត់ឲ្យជាប់ទោសពីបទឧក្រិដ្ឋទាំងនោះឡើយ

ខ. លើកលែងទោសប្រហារជីវិត និងសម្រាលទោសអ្នកដែលរងចាំ ការកាត់ទោសប្រហារជីវិតក្នុងពេលថ្មីៗ ចំពោះឧក្រិដ្ឋកម្ម ដែលទាក់ទងនឹងការយល់ព្រមអោយមានសកម្មភាពផ្លូវភេទ ក្នុងចំណោមមនុស្សដែលគ្រប់អាយុអនុញ្ញាត

គ. បញ្ឈប់រាល់ការឧត្តម្ភ ឬការអនុញ្ញាតឲ្យធ្វើអំពើខុសឆ្គងរបស់រដ្ឋ ទៅលើការរស់នៅរបស់មនុស្សម្នាក់ៗ ដោយសម្អាងលើនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ និងត្រូវធានាថារាល់ការវាយប្រហារទាំងអស់ ទោះជាធ្វើឡើងដោយមន្ត្រីរដ្ឋាភិបាល បុគ្គល ឬក្រុមណាមួយក៏ដោយ ត្រូវធ្វើការស៊ើបអង្កេតយ៉ាងតឹងរឹង ហើយភ័ស្តុតាងពិតប្រាកដត្រូវបានរកឃើញ មនុស្សទាំងនោះ ត្រូវទទួលការផ្តន្ទាទោសការសួរចម្លើយ និងការកាត់ទោសដ៏ត្រឹមត្រូវ ។

## គោលការណ៍ ៥ ៖ សិទ្ធិទទួលបានការការពារសុវត្ថិភាពបុគ្គល

បុគ្គលគ្រប់រូប ដោយមិនគិតពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ មានសិទ្ធិទទួលបានការការពារសុវត្ថិភាពបុគ្គល ហើយនិងសិទ្ធិទទួលបានកិច្ចការពារពីរដ្ឋ ប្រឆាំងរាល់អំពើហិង្សា ឬការធ្វើឲ្យប៉ះពាល់ដល់រាងកាយ មិនថាពីសំណាក់មន្ត្រីរាជការ ឬបុគ្គល ឬក្រុមណាមួយក៏ដោយ ។

**រដ្ឋមានកាតព្វកិច្ចត្រូវ ៖**

ក. អនុវត្តរាល់គោលនយោបាយ និងវិធានការចាំបាច់ផ្សេងៗ ដើម្បីរារាំង និងផ្តល់ការការពារតបតនឹងគ្រប់ទម្រង់ទាំងអស់នៃអំពើហិង្សា និងការបៀតបៀនកេរ្តិ៍ខ្មាស់ ដែលជាប់ទាក់ទងនឹងនិន្នាការភេទ និងអត្តសញ្ញាណភេទយេនឌ័រ

ខ. អនុវត្តវិធានការច្បាប់ចាំបាច់នានា ដើម្បីជំរុញឲ្យមានការដាក់ទោសឧក្រិដ្ឋកម្មដ៏សមស្រប ចំពោះអំពើហិង្សា ការគំរាមកំហែងប្រើប្រាស់អំពើហិង្សា ការញុះញង់បង្កឲ្យមានអំពើហិង្សា និងការបៀតបៀនកេរ្តិ៍ខ្មាស់ ដែលឈរលើមូលដ្ឋាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់បុគ្គល ឬក្រុមណាមួយ លើគ្រប់មជ្ឈដ្ឋាននៃជីវភាព រួមទាំងគ្រួសារផងដែរ

គ. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាថា ជនរងគ្រោះពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ នឹងមិនត្រូវបានគេយកមកប្រើប្រាស់ដើម្បីជាសម្អាង ជាលេស ឬដើម្បីបន្ធូរបន្ថយបទអំពើហិង្សាទាំងនោះឡើយ

ឃ. ត្រូវធានាថា ការប្រព្រឹត្តអំពើហិង្សាទាំងឡាយត្រូវបានស៊ើបអង្កេតយ៉ាងតឹងរឹង ហើយក្នុងករណីដែលភស្តុតាងត្រូវបានរកឃើញគ្រប់គ្រាន់នោះ ជនល្មើសនឹងត្រូវចាប់ផ្តន្ទាទោស កាត់ទោស និងដាក់ទោសសមស្រប ហើយជនរងគ្រោះ ត្រូវបានផ្តល់នូវការប៉ះប៉ូវ និងសំណងដែលខូចខាត រួមទាំងសំណងជាលុយផងដែរ

ង. បង្កើតយុទ្ធនាការលើកកម្ពស់ការយល់ដឹង ដោយផ្ទាល់ទៅកាន់សាធារណជនទូទៅ ក៏ដូចជាទៅកាន់ជនល្មើសប្រព្រឹត្តអំពើហិង្សាជាក់ស្តែង និងដែលត្រូវបានកត់សម្គាល់ ក្នុងគោលបំណងដើម្បីប្រយុទ្ធប្រឆាំងនិងគំនិតបុរេវិនិច្ឆ័យ ដែលបណ្តាលឲ្យមានអំពើហិង្សា ទាក់ទងនឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ។

## គោលការណ៍ ៦ ៖ សិទ្ធិទទួលបានឯកទត្តភាព

បុគ្គលគ្រប់រូប ដោយមិនគិតពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ មានសិទ្ធិទទួលបានឯកទត្តភាព ដោយគ្មានការរំខានដោយអំពើចិត្ត ឬដោយខុសច្បាប់ ចំពោះទាំងជីវភាពគ្រួសារ ផ្ទះសម្បែង ឬការទំនាក់ទំនងនានា ព្រមទាំងទទួលបានកិច្ចការពារ ពីការវាយប្រហារមិនស្របច្បាប់ណាមួយ មកលើកិត្តិយស ឬកិត្តិសព្ទ័របស់បុគ្គលនោះ ។ សិទ្ធិទទួលបានឯកទត្តភាព រួមបញ្ចូល ជាទូទៅ ទាំងជម្រើសក្នុងការបង្ហាញ ឬមិនបង្ហាញព័ត៌មានពាក់ព័ន្ធនឹងនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ក៏ដូចជាការសម្រេចចិត្ត ឬជម្រើសដែលទាក់ទងនឹងរូបរាងកាយផ្ទាល់របស់បុគ្គលណាម្នាក់ និងទំនាក់ទំនងផ្លូវភេទ ដែលព្រមព្រៀងគ្នា និងទំនាក់ទំនងដទៃទៀតជាមួយអ្នកដទៃ ។

**រដ្ឋមានកាតព្វកិច្ចត្រូវ ៖**

ក. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាសិទ្ធិរបស់បុគ្គលម្នាក់ៗ ដោយមិនគិតពីការនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ដើម្បីអាចប្រើប្រាស់លំហឯកជនរបស់ខ្លួន ការសម្រេចចិត្តផ្ទាល់ខ្លួន និងទំនាក់ទំនងជាមួយអ្នកដទៃ រួមទាំងសកម្មភាពផ្លូវភេទដែលមានការព្រមព្រៀងគ្នា ក្នុងចំណោមមនុស្សដែលគ្រប់អាយុអនុញ្ញាត ដោយគ្មានការរំខានយ៉ាយីតាមអំពើចិត្ត

ខ. លុបបំបាត់រាល់ច្បាប់ទាំងឡាយណា ដែលដាក់បទឧក្រិដ្ឋកម្មលើសកម្មភាពផ្លូវភេទ ដែលមានការព្រមព្រៀងគ្នា ក្នុងចំណោមមនុស្សស្រឡាញ់ភេទដូចគ្នា ហើយដែលគ្រប់អាយុអនុញ្ញាត ហើយនិងធានាថា បុគ្គលទាំងឡាយដែលគ្រប់អាយុតាមការកំណត់ អាចប្រើប្រាស់សិទ្ធិខ្លួន សម្រាប់ប្រព្រឹត្តសកម្មភាពផ្លូវភេទជាមួយអ្នកមានភេទដូចគ្នា និងភេទខុសគ្នាបានស្មើភាពគ្នា

គ. ធានាថាច្បាប់ឧក្រិដ្ឋ និងបញ្ញត្តិផ្សេងៗនៃការអនុវត្តជាទូទៅ មិនត្រូវបានអនុវត្ត ជាបទឧក្រិដ្ឋកម្មចំពោះសកម្មភាពផ្លូវភេទ ដែលព្រមព្រៀងគ្នា ក្នុងចំណោមមនុស្សស្រឡាញ់ភេទដូចគ្នា ហើយដែលគ្រប់អាយុអនុញ្ញាតនោះទេ

ឃ. លុបបំបាត់ចោលច្បាប់ទាំងឡាយណា ដែលហាមឃាត់ ឬដាក់ជាបទឧក្រិដ្ឋកម្ម ចំពោះការបង្ហាញអត្តសញ្ញាណយេនឌ័រ រាប់បញ្ចូលទាំងតាមរយៈការស្លៀកពាក់ ការប្រើពាក្យសម្តី ឬចរិយាមាយាទ ឬការប្រានចោលនូវឱកាសរបស់បុគ្គលទាំងអស់ ក្នុងការកែប្រែរូបរាងកាយរបស់ពួកគេ ដើម្បីជាមធ្យោបាយបង្ហាញអត្តសញ្ញាណយេនឌ័រ របស់ពួកគេនោះឡើយ

ង. លើកលែងការដាក់ឃុំឃាំង និងការផ្តន្ទាទោស លើបទឧក្រិដ្ឋកម្មទាំងឡាយណា ទាក់ទងនឹងសកម្មភាពផ្លូវភេទដែលមានការព្រមព្រៀងគ្នា ក្នុងចំណោមមនុស្សដែលគ្រប់អាយុអនុញ្ញាត ឬដែលទាក់ទងនឹងអត្តសញ្ញាណយេនឌ័រ

ច. ត្រូវធានាថា បុគ្គលគ្រប់រូបមានសិទ្ធិជាធម្មតា ក្នុងការជ្រើសរើសពេលវេលា ទៅកាន់នរណាម្នាក់ និងដោយមធ្យោបាយណាមួយ ដើម្បីលាតត្រដាងព័ត៌មានដែលទាក់ទងនឹងនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័ររបស់ពួកគេ ព្រមទាំងធានានូវការទទួលបានការការពារ ពីការឲ្យលាតត្រដាងព័ត៌មានតាមអំពើចិត្ត និងដែលបុគ្គលសាមីមិនចង់បង្ហាញ ឬការគំរាមគំហែងឲ្យលាតត្រដាងព័ត៌មានទាំងនេះពីសំណាក់អ្នកដទៃ ។

## គោលការណ៍ ៧ ៖ សិទ្ធិរួចផុតពីការដកហូតសេរីភាពដោយបំពាន

គ្មានជនណាម្នាក់ ត្រូវចាប់ខ្លួន ឬឃុំខ្លួនដោយបំពានបានឡើយ ។ រាល់ការចាប់ខ្លួន ឬឃុំខ្លួន ដែលឈរលើមូលដ្ឋាននៃនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ មិនថាអនុលោមតាមដីកាតុលាការឬយ៉ាងណានោះទេ គឺជាសកម្មភាពបំពាន ។ បុគ្គលគ្រប់រូបដែលស្ថិតក្រោមការចាប់ខ្លួន ដោយមិនប្រកាន់ពីនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ មានសិទ្ធិស្មើៗគ្នាក្នុងការដឹងពីមូលហេតុនៃការចាប់ខ្លួន និងលក្ខខណ្ឌនៃការចោទប្រកាន់នានាមកលើខ្លួន, ក្នុងការត្រូវបានគេនាំខ្លួនទៅចំពោះមុខមន្ត្រីចៅក្រមភ្លាមៗ, និងក្នុងការទទួលបានការជំនុំជំរះ ដើម្បីកំណត់ពីភាពស្របច្បាប់នៃការឃុំខ្លួន មិនថាត្រូវបានចោទប្រកាន់ពីបទល្មើសណាមួយ ឬយ៉ាងណានោះទេ ។

**រដ្ឋមានកាតព្វកិច្ចត្រូវ ៖**

ក. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាថា និន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ទោះក្នុងកាលៈទេសៈណាក៏ដោយ នឹងមិនត្រូវបានយកជាមូលដ្ឋាននៃការចាប់ខ្លួន ឬឃុំខ្លួននោះឡើយ នេះដោយរាប់ទាំងការលុបចោលបណ្ដាបញ្ញត្តិច្បាប់ព្រហ្មទណ្ឌនានា ដែលប្រើពាក្យមិនច្បាស់លាស់ ជាហេតុអាចបង្កឲ្យមានការអនុវត្តច្បាប់ដោយរើសអើង ឬផ្ដល់ឱកាសចាប់ខ្លួនដោយឈរលើមូលដ្ឋាននៃចន្លោះប្រហោងច្បាប់បែបនេះ

ខ. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាថា បុគ្គលគ្រប់រូបដែលស្ថិតក្រោមការចាប់ខ្លួន ដោយមិនប្រកាន់ពីនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ មានសិទ្ធិស្មើៗគ្នាក្នុងការដឹងពីមូលហេតុនៃការចាប់ខ្លួន និងលក្ខខណ្ឌនៃការចោទប្រកាន់នានាមកលើខ្លួន, ក្នុងការត្រូវបានគេនាំខ្លួនទៅចំពោះមុខមន្ត្រីចៅក្រមភ្លាមៗ, និងក្នុងការទទួលបានការជំនុំជំរះ ដើម្បីកំណត់ពីភាពស្របច្បាប់នៃការឃុំខ្លួន

គ. បង្កើតកម្មវិធីបណ្ដុះបណ្ដាល និងលើកកម្ពស់ការយល់ដឹង ដល់មន្ត្រីប៉ូលីស និងមន្ត្រីអនុវត្តច្បាប់ទាំងអស់ឲ្យយល់ថាការចាប់ខ្លួន ឬឃុំខ្លួនដែលឈរលើមូលដ្ឋាននៃនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ គឺជាការបំពាន

ឃ. រក្សាឲ្យបាននូវកំណត់ត្រា ដែលមានសុក្រឹតភាព និងត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ អំពីការចាប់ខ្លួន និងឃុំខ្លួនទាំងឡាយ ដោយបញ្ជាក់ពីកាលបរិច្ឆេទ ទីតាំង និងមូលហេតុនៃការឃុំខ្លួន ព្រមទាំងធានាថាឲ្យមានការត្រួតពិនិត្យទីតាំងឃុំឃាំងទាំងនោះ ដោយស្ថាប័នឯករាជ្យ ដែលត្រូវបានផ្ដល់អាណត្តិ និងលទ្ធភាពគ្រប់គ្រាន់ ក្នុងការកំណត់លើរាល់ការចាប់ខ្លួន និងការឃុំខ្លួន ដែលអាចបណ្ដាលមកពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័ររបស់បុគ្គលណាម្នាក់នោះ ។

## គោលការណ៍ ៨ ៖ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

ជនគ្រប់រូបត្រូវមានសិទ្ធិឲ្យសាលាក្ដីដែលមានសមត្ថកិច្ច ឯករាជ្យ មិនលម្អៀង និងដែលត្រូវបានបង្កើតឡើងដោយច្បាប់ ជំនុំជម្រះរឿងក្ដីរបស់ខ្លួនប្រកបដោយសមធម៌និងជាសាធារណៈ ដើម្បីកំណត់អំពីសិទ្ធិនិងករណីយកិច្ចរបស់ខ្លួន ទាំងក្នុងបណ្ដឹងរដ្ឋប្បវេណី និងក្នុងបទចោទប្រកាន់ព្រហ្មទណ្ឌប្រឆាំងមកលើខ្លួន ដោយមិនលម្អៀង និងដោយគ្មានការរើសអើងពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រឡើយ ។

**រដ្ឋមានកាតព្វកិច្ចត្រូវ ៖**

ក. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីហាមឃាត់ និងលុបបំបាត់ការប្រតិបត្តិល្អៀង ដែលឈរលើមូលដ្ឋាន នៃនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ នៅរាល់ដំណាក់កាលទាំងអស់នៃការជំនុំជម្រះក្តី ទាំងចំពោះការកាត់សេចក្តី លើបណ្តឹងរដ្ឋប្បវេណីនិងព្រហ្មទណ្ឌ និងចំពោះរាល់នីតិវិធីតុលាការនិងរដ្ឋបាលនានា ដែលកំណត់អំពីសិទ្ធិនិងករណីកិច្ច ហើយធានាថា គ្មានបុគ្គលណាម្នាក់ត្រូវបានដកសេចក្តីទុកចិត្ត ឬចរិតលក្ខណៈក្នុងការធ្វើជាភាគីបណ្តឹង ជាសាក្សី ជាអ្នកគាំទ្រ ឬជាអ្នកសម្រេចចិត្ត ដោយសារហេតុផលនៃនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រនោះឡើយ

ខ. ចាត់វិធានការចាំបាច់និងសមហេតុផលនានា ដើម្បីការពារបុគ្គលទាំងឡាយ ពីការផ្តន្ទាទោសរដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ដែលត្រូវបានជំរុញឡើងទាំងស្រុងឬដោយផ្នែក ដោយកត្តានិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ

គ. បង្កើតកម្មវិធីបណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹងផ្សេងៗ ដល់ចៅក្រម មន្ត្រីតុលាការ ព្រះរាជអាជ្ញា មេធាវី និងបុគ្គលិកដទៃទៀត អំពីស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ និងគោលការណ៍សមភាព និងមិនរើសអើង ដោយរួមបញ្ចូលទាំងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ។

## គោលការណ៍ ៩ ៖ សិទ្ធិទទួលបានកិច្ចគាំពារប្រកបដោយមនុស្សធម៌ ក្នុងពេលជាប់ឃុំឃាំង

បុគ្គលគ្រប់រូបដែលត្រូវបានដកហូតសេរីភាព ត្រូវតែទទួលបានកិច្ចគាំពារប្រកបដោយមនុស្សធម៌ និងដោយក្តីគោរពអំពីសេចក្តីថ្លៃថ្នូរនៃមនុស្សជាតិ ។ និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ គឺជាផ្នែកមួយរបស់សេចក្តីថ្លៃថ្នូរនៃមនុស្សជាតិនេះ ។

**រដ្ឋមានកាតព្វកិច្ចត្រូវ ៖**

ក. ធានាថាការដាក់ឃុំឃាំងទាំងឡាយ មិនបានធ្វើឲ្យបុគ្គលណាម្នាក់ ត្រូវបានធ្វើឲ្យកាន់តែដាច់ឆ្ងាយពីអ្នកដទៃ ដោយសារតែនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ឬត្រូវបានប្រឈមនឹងការបំពានដោយប្រើអំពើហឹង្សា ប្រណិតបត់ន៍មិនសមរម្យ ឬបំពានដល់ផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ ជាដើម

ខ. ផ្តល់ការព្យាបាលតាមបែបវិជ្ជសាស្ត្រឲ្យបានគ្រប់គ្រាន់ និងការពិគ្រោះយោបល់ ដែលសមស្របទៅនឹងសេចក្តីត្រូវការរបស់អ្នកដែលជាប់នៅក្នុងមន្ទីរឃុំឃាំង ដោយទទួលស្គាល់សេចក្តីត្រូវការរបស់បុគ្គលទាំងឡាយ ដែលផ្អែកលើនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ រាប់បញ្ចូលទាំងសុខភាពបន្តពូជ ការទទួលបានព័ត៌មានស្តីពីរោគអេដស៍ និងការព្យាបាល ព្រមទាំងលទ្ធភាពទទួលបានការព្យាបាលអរម៉ូន ឬការព្យាបាលរោគផ្សេងៗ ក៏ដូចជាការព្យាបាលវះកាត់ប្តូរភេទតាមការចាំបាច់

គ. ធានាថាអ្នកទោសទាំងអស់ មានសិទ្ធិចូលរួមសម្រេចចិត្ត តាមតែអាចធ្វើទៅបាន ចំពោះកន្លែងឃុំឃាំងដែលសមស្របតាមនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់ពួកគេ

ឃ. ដាក់ចេញនូវវិធានការការពារផ្សេងៗ សម្រាប់អ្នកទោសទាំងអស់ដែលងាយរងគ្រោះពីអំពើហិង្សា ឬការរំលោភបំពាន ដែលកើតចេញពីនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ ឬចេញពីការបង្ហាញចរិតលក្ខ

ណៈភេទ ហើយធានាថា រាល់វិធានការការពារបែបនោះ មិនបានរារាំងសិទ្ធិរបស់ពួកគេ ជាងការទទួលបានបទពិសោធន៍កន្លងមកពីអ្នកទោសទូទៅនោះទេ

ង. ធានាថាការមកសួរសុខទុក្ខរបស់សហព័ទ្ធដែលត្រូវបានអនុញ្ញាត ត្រូវបានផ្តល់សិទ្ធិស្មើៗគ្នា ដល់អ្នកទោស និងអ្នកជាប់ឃុំឃាំងទាំងអស់ ដោយមិនគិតពីយេនឌ័រនៃសហព័ទ្ធរបស់អ្នកទាំងនោះឡើយ

ច. អនុញ្ញាតឲ្យមានការតាមដានមន្ទីរឃុំឃាំងដោយឯករាជ្យ ពីសំណាក់រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល រួមទាំងអង្គការដែលធ្វើសកម្មភាពលើនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រផងដែរ

ឆ. បង្កើតកម្មវិធីបណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹង ស្តីពីស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ និងគោលការណ៍សមភាព និងមិនរើសអើង រួមបញ្ចូលទាំងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រផងដែរ ដល់មន្ត្រីពន្ធនាគារ និងមន្ត្រីរាជការ ទាំងក្នុងវិស័យឯកជន និងសាធារណៈទាំងអស់ ដែលធ្វើការងារពាក់ព័ន្ធនឹងមន្ទីរឃុំឃាំង ។

## គោលការណ៍ ១០ ៖ សិទ្ធិរួចផុតពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប

បុគ្គលគ្រប់រូបមានសិទ្ធិរួចផុតពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប រាប់ទាំងពីហេតុនៃនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រផង ។

**រដ្ឋមានកាតព្វកិច្ចត្រូវ ៖**

ក. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីរារាំងនិងផ្តល់កិច្ចការពារពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ប្រព្រឹត្តិឡើងពីហេតុនៃនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់ជនរងគ្រោះ ព្រមទាំងការញុះញង់ឲ្យប្រព្រឹត្តសកម្មភាពទាំងនេះ

ខ. ចាត់វិធានការសមហេតុផលនានា ដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះ ដែលបណ្តាលមកពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ដែលត្រូវបានប្រព្រឹត្តឡើង ដោយហេតុនៃនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ព្រមទាំងផ្តល់សំណងសមស្រប ដោយរួមទាំងការប៉ះប៉ូវ និងការជួសជុលការខូចខាត ហើយបើអាចធ្វើទៅបាន ជួយគាំទ្រផ្នែកវេជ្ជសាស្រ្ត និងចិត្តសាស្រ្តផងដែរ

គ. បង្កើតកម្មវិធីបណ្តុះបណ្តាល និងការលើកកម្ពស់ការយល់ដឹងផ្សេងៗ ដល់មន្ត្រីប៉ូលីស មន្ត្រីពន្ធនាគារ និងមន្ត្រីដទៃទៀត ទាំងក្នុងវិស័យឯកជន និងសាធារណៈទាំងអស់ ដែលមាននាទីក្នុងការប្រព្រឹត្ត ឬរារាំងសកម្មភាពទាំងនេះ ។

## គោលការណ៍ ១១ ៖ សិទ្ធិទទួលបានកិច្ចការពារ ពីរាល់ទម្រង់នៃការកេងប្រវ័ញ្ច ការធ្វើអាជីវកម្ម និងការជួញដូរមនុស្ស

បុគ្គលគ្រប់រូប មានសិទ្ធិទទួលបានកិច្ចការពារពីការជួញដូរ ការធ្វើអាជីវកម្ម និងពីរាល់ទម្រង់នៃការកេងប្រវ័ញ្ច ដោយរួមបញ្ចូលតែមិនកំណត់ត្រឹមប៉ុណ្ណឹង នូវការកេងប្រវ័ញ្ចផ្លូវភេទដែលផ្អែកលើមូលដ្ឋានជាក់ស្តែង ឬការយល់ឃើញពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ។ រាល់វិធានការផ្សេងៗដែលបង្កើតឡើង ដើម្បីរារាំងការជួញដូរមនុស្ស គួរត្រូវបានធ្វើឡើងដើម្បីដោះស្រាយចំពោះកត្តានានា ដែលធ្វើឲ្យកើនឡើងនូវភាពងាយរងគ្រោះ ដោយរួមទាំងទម្រង់វិសមភាព និងការរើសអើងតាមរូបភាពជាច្រើន ទៅលើមូលដ្ឋានជាក់ស្តែង ឬការយល់ឃើញពីនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ ឬការសម្តែងពីអត្តសញ្ញាណឯទៀត ។ វិធានការទាំងនេះ មិនត្រូវផ្ទុយពីគោលការណ៍សិទ្ធិមនុស្សរបស់បុគ្គលទាំងឡាយ ដែលនឹងអាចប្រឈមនឹងគ្រោះថ្នាក់នៃការជួញដូរឡើយ ។

**រដ្ឋមានកាតព្វកិច្ចត្រូវ ៖**

ក. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដែលមានលក្ខណៈទប់ស្កាត់ និងការពារ ពីការជួញដូរ ការធ្វើអាជីវកម្ម និងពីរាល់ទម្រង់នៃការកេងប្រវ័ញ្ចមនុស្ស ដោយរួមបញ្ចូលទាំងតែមិនកម្រិតត្រឹមប៉ុណ្ណឹង នូវការកេងប្រវ័ញ្ចផ្លូវភេទ ដោយសារមូលដ្ឋានជាក់ស្តែង ឬការយល់ឃើញពីនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ

ខ. ធានាថាច្បាប់ ឬវិធានការផ្សេងៗ មិនដាក់បទឧក្រិដ្ឋកម្ម ក្នុងអាកប្បកិរិយាដែលធ្វើឲ្យមានភាពមិនពេញចិត្ត ឬម្យ៉ាងទៀត អាចធ្វើឲ្យស្ថានភាពជនងាយរងគ្រោះទាំងនោះរឹតតែធ្ងន់ធ្ងរ

គ. បង្កើតវិធានការខាងនីតិបញ្ញត្តិ ខាងការអប់រំ និងខាងសង្គមកិច្ច, សេវាកម្ម, និងកម្មវិធីផ្សេងៗ ដើម្បីដោះស្រាយកត្តានានា ដែលបង្កើនភាពងាយរងគ្រោះពីការជួញដូរ ការធ្វើអាជីវកម្ម និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ទាំងអស់ រួមបញ្ចូលទាំងតែមិនកម្រិតតែចំពោះការកេងប្រវ័ញ្ចផ្លូវភេទ ដែលផ្អែកលើមូលដ្ឋាន ជាក់ស្តែង ឬការយល់ឃើញពីនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រនោះទេ ដែលនេះនឹងបណ្តាលឲ្យមានការមិនរាប់រកពីសង្គម ការរើសអើង ការបដិសេធពីគ្រួសារ ឬសហគមន៍វប្បធម៌ កង្វះឯករាជ្យភាពខាងហិរញ្ញវត្ថុ ខ្វះផ្ទះសំបែង ឥរិយាបថនៃការរើសអើងពីសង្គមធ្វើឲ្យមានការធ្លាក់ទឹកចិត្ត និងកង្វះកិច្ចការពារពីការរើសអើង ក្នុងការទទួលបាននូវផ្ទះសំបែង ទីស្នាក់អាស្រ័យ ការងារ និងសេវាសង្គមផ្សេងៗទៀត ។

## គោលការណ៍ ១២ ៖ សិទ្ធិទទួលបានការងារធ្វើ

មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការងារធ្វើ ជ្រើសរើសការងារដោយសេរី ទទួលបានលក្ខខណ្ឌការងារត្រឹមត្រូវនិងពេញចិត្ត និងមានកិច្ចការពារប្រឆាំងនឹងភាពអត់ការងារធ្វើ ដោយមិនមានការរើសអើង ពីហេតុនៃនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រនោះឡើយ ។

**រដ្ឋមានកាតព្វកិច្ចត្រូវ ៖**

ក. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីលុបបំបាត់ និងហាមឃាត់ការរើសអើងទៅលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ទាំងសម្រាប់ការងារសាធារណៈនិងឯក

ជន ដែលរួមបញ្ចូលទាំងការបណ្តុះបណ្តាលការងារ ការជ្រើសរើសបុគ្គលិក ការតម្លើងឋានៈ ការបញ្ឈប់ពីការងារ លក្ខខណ្ឌការងារ និងការទទួលបានលាភការ

ខ. លុបបំបាត់ការរើសអើងផ្សេងៗ ដោយសារមូលដ្ឋាននៃនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ដើម្បីធានាថា បុគ្គលម្នាក់ៗអាចទទួលបានការងារ និងឱកាសអភិវឌ្ឍន៍ខ្លួន ក្នុងគ្រប់វិស័យសេវាកម្មសាធារណៈ ដោយរួមបញ្ចូលទាំងសេវាកម្មរដ្ឋាភិបាល និងការងារក្នុងមុខងារសាធារណៈ ដូចជាការបម្រើការងារជាមន្ត្រីប៉ូលីស និងយោធា និងផ្តល់កម្មវិធីបណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹងដ៏សមស្រប ដើម្បីប្រឆាំងនឹងឥរិយាបទរើសអើង ។

## គោលការណ៍ ១៣ ៖ សិទ្ធិទទួលបានសុវត្ថិភាពសង្គម និងវិធានការការពារសង្គមឯទៀត

បុគ្គលគ្រប់រូប មានសិទ្ធិទទួលបានសុវត្ថិភាពសង្គម និងវិធានការការពារសង្គមឯទៀត ដោយគ្មានការរើសអើងដោយសារនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រនោះឡើយ ។

**រដ្ឋមានកាតព្វកិច្ចត្រូវ ៖**

ក. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាឲ្យបានលទ្ធភាពទទួលបានស្មើៗគ្នា នូវសុវត្ថិភាពសង្គម និងវិធានការការពារសង្គមឯទៀត ដោយគ្មានការរើសអើងពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ រួមបញ្ចូលទាំងផលប្រយោជន៍ពីការងារ ការសម្រាកសម្រាលកូន ផលប្រយោជន៍ពេលគ្មានការងារធ្វើ ការធានារ៉ាប់រងសុខភាព ឬការថែទាំឬផលប្រយោជន៍ (រួមទាំងការផ្លាស់ប្តូរសរីរាង្គកាយ ដែលទាក់ទងនឹងអត្តសញ្ញាណយេនឌ័រ) ការធានារ៉ាប់រងសង្គមឯទៀត ផលប្រយោជន៍សម្រាប់គ្រួសារ ផលប្រយោជន៍បុណ្យសព ប្រាក់សោធន និងផលប្រយោជន៍ទាក់ទងនឹងការបាត់បង់ការផ្គត់ផ្គង់របស់ប្តីប្រពន្ធ ឬដៃគូដែលបណ្តាលមកពីជំងឺ ឬមរណភាព

ខ. ធានាថាកុមារគ្រប់រូប មិនត្រូវបានរើសអើង ក្នុងការផ្តល់ប្រព័ន្ធសុវត្ថិភាពសង្គម ឬបញ្ញត្តិប្រយោជន៍សុខមាលភាពផ្សេងទៀត ដោយសារតែនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ ឬដោយសារសមាជិកដទៃនៃគ្រួសាររបស់កុមារនោះឡើយ

គ. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាថាបុគ្គលគ្រប់រូប អាចទទួលបានផលប្រយោជន៍ពីយុទ្ធសាស្ត្រ និងកម្មវិធីកាត់បន្ថយភាពក្រីក្រ ដោយគ្មានការរើសអើងលើនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ នោះឡើយ ។

## គោលការណ៍ ១៤ ៖ សិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់

បុគ្គលគ្រប់រូប មានសិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ រួមមាន ចំណីអាហារ ការបរិភោគទឹកស្អាត អនាម័យ និងសម្លៀកបំពាក់គ្រប់គ្រាន់ ព្រមទាំងការប្រសើរឡើងជាលំដាប់ នៃលក្ខខណ្ឌរស់នៅរបស់បុគ្គលម្នាក់ៗ ដោយគ្មានការរើសអើងនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ។

**រដ្ឋមានកាតព្វកិច្ចត្រូវ ៖**

ក. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាថា បុគ្គលគ្រប់រូប អាចទទួលបានស្មើៗគ្នា នូវចំណីអាហារ ការបរិភោគទឹកស្អាត អនាម័យ និងសម្លៀកបំពាក់ គ្រប់គ្រាន់ ដោយគ្មានការរើសអើងនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ។

## គោលការណ៍ ១៥ ៖ សិទ្ធិ ទទួលបានទីលំនៅគ្រប់គ្រាន់

បុគ្គលគ្រប់រូបមានសិទ្ធិទទួលបានទីលំនៅគ្រប់គ្រាន់ រួមទាំងកិច្ចការពារពីការបណ្តេញចេញ ដោយគ្មានការរើសអើងនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ នោះឡើយ ។

**រដ្ឋមានកាតព្វកិច្ចត្រូវ ៖**

ក. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានានូវសិទ្ធិរបស់ជនគ្រប់រូបក្នុងការទទួលបានសុវត្ថិភាពលំនៅដ្ឋាន និងទីលំនៅសមរម្យ ដែលអាចរស់នៅបាន ដែលអាចទទួលយកបាន សមស្របតាមវប្បធម៌ប្រពៃណី និងសុវត្ថិភាព រាប់ទាំងជម្រកនិងទីស្នាក់អាស្រ័យបន្ទាន់ផ្សេងៗទៀត ដោយគ្មានការរើសអើងនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ឬស្ថានភាពប្តីប្រពន្ធ ឬគ្រួសារឡើយ

ខ. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាឲ្យបាននូវការហាមឃាត់ចំណាត់ការបណ្តេញចេញ ដែលមិនអនុលោមតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ និងធានាឲ្យបាននូវការការពារដោយច្បាប់ គ្រប់គ្រាន់ និងប្រសិទ្ធភាព ឬសំណងសមស្របផ្សេងទៀត ដល់បុគ្គលទាំងឡាយ ដែលបានអះអាងថា សិទ្ធិទទួលបានការការពារប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំរបស់ខ្លួនត្រូវបានរំលោភបំពាន ឬស្ថិតក្រោមការគំរាមកំហែង រួមទាំងសិទ្ធិទទួលបាននូវការតាំងទីលំនៅជាថ្មី ដែលរួមមានសិទ្ធិនៃការជ្រើសរើសដីធ្លី ដើម្បីអោយមានភាពប្រសើរឡើង ឬស្មើៗគ្នា ហើយដើម្បីឲ្យមានសិទ្ធិគ្រប់គ្រាន់ក្នុងការមានទីលំនៅគ្រប់គ្រាន់ ដោយគ្មានការរើសអើងនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ឬស្ថានភាពប្តីប្រពន្ធ ឬគ្រួសារ នោះឡើយ

គ. ធានាឲ្យបាននូវសិទ្ធិស្មើៗគ្នា ក្នុងការកាន់កាប់ដីធ្លី និងផ្ទះសំបែង ព្រមទាំងការទទួលមរតក ដោយគ្មានការរើសអើងនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ

ឃ. បង្កើតកម្មវិធីសង្គម រួមទាំងកម្មវិធីគាំទ្រផ្សេងៗ ដើម្បីដោះស្រាយកត្តាដែលទាក់ទងនឹងនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ដែលអាចបង្កើនឡើងនូវភាពងាយរងគ្រោះ ចំពោះអ្នកដែលគ្មានផ្ទះសំបែង ជាពិសេសចំពោះកុមារ និងយុវជន រួមមានទាំងការមិនទទួលស្គាល់ពីសង្គម អំពើហិង្សាក្នុងគ្រួសារ និងទម្រង់នៃអំពើហិង្សាផ្សេងទៀត ការរើសអើង ការខ្វះខាតភាពម្ចាស់ការលើហិរញ្ញវត្ថុ និងការមិនទទួលស្គាល់ពីគ្រួសារឬសហគមន៍ ក៏ដូចជាការបង្កើតផែនការគាំទ្រ និងសុវត្ថិភាពពីអ្នកជិតខាង

ង. បង្កើតកម្មវិធីបណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹងផ្សេងៗ ដើម្បីធានាថាភ្នាក់ងារពាក់ព័ន្ធទាំងអស់បានយល់ដឹង និងជ្រួតជ្រាបពីតម្រូវការរបស់អ្នកដែលប្រឈមមុខនឹងភាពគ្មានផ្ទះសំបែង ឬផលប៉ះពាល់អាក្រក់ពីសង្គម ដែលជាលទ្ធផលពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ។

## គោលការណ៍ ១៦ ៖ សិទ្ធិទទួលបានការអប់រំ

បុគ្គលគ្រប់រូប មានសិទ្ធិទទួលបានការអប់រំ ដោយគ្មានការរើសអើងនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ។

**រដ្ឋមានកាតព្វកិច្ចត្រូវ ៖**

ក. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាថា បុគ្គលម្នាក់ៗទទួលបានការអប់រំស្មើៗគ្នា និងការប្រព្រឹត្តមកលើខ្លួនដោយស្មើភាព ពីសំណាក់សិស្សានុសិស្ស បុគ្គលិក និងគ្រូបង្រៀន នៅក្នុងប្រព័ន្ធអប់រំ ដោយគ្មានការរើសអើងនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ

ខ. ធានាថាការអប់រំ ត្រូវបានធ្វើឡើងដោយផ្ទាល់ ដើម្បីអភិវឌ្ឍបុគ្គលិកលក្ខណៈ ទេពកោសល្យ និងសមត្ថភាពប្រាជ្ញានិងកាយសម្បទា ដល់សិស្សម្នាក់ៗ ឲ្យទទួលបានសក្តានុពលដ៏ពេញលេញ និងឆ្លើយតបនឹងសេចក្តីត្រូវការរបស់សិស្ស ដែលមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រគ្រប់ប្រភេទ

គ. ធានាថាការអប់រំ ត្រូវបានធ្វើឡើងដោយផ្ទាល់ ដើម្បីលើកកម្ពស់ការគោរពសិទ្ធិមនុស្ស និងការគោរពឪពុកម្តាយរបស់សិស្សម្នាក់ៗ និងសមាជិកគ្រួសារ អត្តសញ្ញាណវប្បធម៌ ភាសា និងគុណតម្លៃ ក្នុងន័យលើកកម្ពស់ការយល់ដឹងពីសន្តិភាព ភាពអត់អោន និងសមភាព ដោយមានការបញ្ចូល និងគោរពដល់និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ដែលមានលក្ខណៈចម្រុះបែប

ឃ. ធានាថាវិធីសាស្ត្រអប់រំ កម្មវិធីសិក្សា និងធនធាននានា ជួយពង្រឹងដល់ការយល់ដឹង និងការគោរពចំពោះនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រដែលមានលក្ខណៈចម្រុះបែប ដោយរួមបញ្ចូលទាំងតម្រូវការរបស់សិស្ស ឪពុកម្តាយ និងសមាជិកគ្រួសាររបស់ពួកគេ ដែលជាប់ទាក់ទងនឹងអត្តសញ្ញាណបែបនេះ

ង. ធានាថាទាំងច្បាប់ និងប៉ូលីស បានផ្តល់កិច្ចការពារគ្រប់គ្រាន់ ដល់សិស្សានុសិស្ស បុគ្គលិក និងគ្រូបង្រៀន ដែលមាននិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រខុសពីគេ ដើម្បីប្រឆាំងរាល់ទម្រង់នៃការមិនទទួលស្គាល់ពីសង្គម និងអំពើហិង្សានៅតាមមជ្ឈដ្ឋានសាលារៀន រួមទាំងការសម្លុតគំរាមកំហែង និងការបៀតបៀនកេរ្តិ៍ខ្មាស់

ច. ធានាថា សិស្សដែលរងការមិនទទួលស្គាល់ពីសង្គម ឬអំពើហិង្សាបែបនេះ មិនត្រូវបានទុកចោល ឬបំបែកទៅម្ខាង ដោយហេតុផលនៃការការពារ ហើយធានាថា ផលប្រយោជន៍ល្អប្រសើររបស់ពួកគេត្រូវកំណត់យ៉ាងច្បាស់និងគោរពតាម ដោយមានការចូលរួមទាំងអស់គ្នា

ឆ. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាថា គោលវិន័យនៅតាមស្ថាប័នអប់រំត្រូវបានតាក់តែងឡើង ឲ្យសមស្របនឹងសេចក្តីថ្លៃថ្នូររបស់មនុស្ស ដោយគ្មានការរើសអើង ឬការដាក់ពិន័យលើនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ឬការសម្តែងពីអត្តសញ្ញាណទាំងនេះឡើយ

ជ. ធានាថាបុគ្គលគ្រប់រូបទទួលបានឱកាស និងធនធានសម្រាប់រៀនពេញមួយជីវិត ដោយគ្មានការរើសអើងនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ រួមមាន យុវជនដែលធ្លាប់ទទួលរងការរើសអើងគ្រប់ទម្រង់ទាំងអស់ក្នុងប្រព័ន្ធអប់រំ ។

## គោលការណ៍ ១៧ ៖ សិទ្ធិទទួលបានកម្រិតសុខភាពខ្ពស់បំផុត តាមដែលអាចធ្វើទៅបាន

បុគ្គលគ្រប់រូប មានសិទ្ធិទទួលបានកម្រិតសុខភាពទាំងខាងរាងកាយ និងខាងស្មារតីខ្ពស់បំផុត តាមដែលអាចធ្វើទៅបាន ដោយគ្មានការរើសអើងពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រនោះឡើយ ។ សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ គឺជាទិដ្ឋភាពមូលដ្ឋាននៃសិទ្ធិនេះ ។

**រដ្ឋមានកាតព្វកិច្ចត្រូវ ៖**

ក. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាសម្រេចបានការប្រើប្រាស់ពេញលេញនូវសិទ្ធិទទួលបានកម្រិតសុខភាពខ្ពស់បំផុត តាមដែលអាចធ្វើទៅបាន ដោយគ្មានការរើសអើងពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រនោះឡើយ

ខ. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាថា បុគ្គលគ្រប់រូបទទួលបានសេវាថែទាំសុខភាព ទំនិញ និងសេវាកម្មផ្សេងៗ ដែលពាក់ព័ន្ធនឹងសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ ហើយកំណត់ត្រាសុខភាពផ្ទាល់ខ្លួនរបស់ពួកគេ ដោយគ្មានការរើសអើងពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ

គ. ធានាថាសេវាថែទាំសុខភាព ទំនិញ និងសេវាកម្មផ្សេងៗ ត្រូវបានបង្កើតឡើងដើម្បីជួយលើកកម្ពស់ស្ថានភាពសុខភាព និងឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់មនុស្សគ្រប់រូប ដោយគ្មានការរើសអើងពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រនោះឡើយ ហើយព្រមទាំងធានាថារាល់កំណត់ត្រាព្យាបាលរបស់បុគ្គលម្នាក់ៗ ត្រូវបានរក្សាភាពសម្ងាត់

ឃ. បង្កើតនិងអនុវត្តកម្មវិធីនានា ដើម្បីដោះស្រាយបញ្ហារើសអើង គំនិតបុរេវិនិច្ឆ័យ និងកត្តាសង្គមផ្សេងទៀត ដែលបង្កមហន្តរាយដល់សុខភាពមនុស្ស ពីហេតុនៃនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ

ង. ធានាថាបុគ្គលគ្រប់រូប ទទួលបានព័ត៌មាន និងមានអំណាចធ្វើការសម្រេចចិត្តដោយខ្លួនឯង ទាក់ទងនឹងការថែទាំ និងការព្យាបាលវេជ្ជសាស្ត្រ ដោយផ្អែកលើព័ត៌មានពិតប្រាកដដែល ទទួលបានដោយគ្មានការរើសអើងពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រនោះឡើយ

ច. ធានាថារាល់បញ្ហាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ការអប់រំ ការទប់ស្កាត់ កម្មវិធីព្យាបាល និងសេវាថែទាំ និងសេវាកម្មផ្សេងទៀត ផ្តោតលើភាពចម្រុះបែបនៃនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ហើយរាល់សេវាកម្មទាំងនេះ ត្រូវបានផ្តល់ជូនដល់បុគ្គលគ្រប់រូបស្មើៗគ្នា ដោយគ្មានការរើសអើង

ឆ. ផ្តល់ភាពងាយស្រួលដល់បុគ្គលទាំងឡាយណា ដែលស្វែងរកការកែប្រែរាងកាយ ដែលជាប់ទាក់ទងនឹងការវះកាត់ប្តូរភេទ ក្នុងការទទួលបានការព្យាបាល ការថែទាំ និងគាំទ្រយ៉ាងពេញសមត្ថភាព និងដោយគ្មានការរើសអើង

ជ. ធានាថារាល់អ្នកផ្តល់សេវាសុខភាពទាំងអស់ ប្រព្រឹត្តមកលើអតិថិជន និងដៃគូរបស់ពួកគេ រួមទាំងអ្នកដែលចាត់ទុកថាជាញាតិសន្តានជំនាន់ក្រោយ ដោយគ្មានការរើសអើងលើនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រនោះឡើយ

ឈ. អនុម័តគោលនយោបាយ និងកម្មវិធីអប់រំនិងបណ្តុះបណ្តាល ដែលចាំបាច់អាចធ្វើឲ្យអ្នកដែលធ្វើការលើវិស័យសុខភាព អាចផ្តល់កម្រិតថែទាំសុខភាពខ្ពស់បំផុតតាមដែលអាចធ្វើទៅបាន ចំពោះបុគ្គលគ្រប់រូប ប្រកបដោយការគោរពចំពោះនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ។

## គោលការណ៍ ១៨ ៖ កិច្ចការពារពីការបំពានខាងវេជ្ជសាស្ត្រ

គ្មានបុគ្គលណាម្នាក់ អាចត្រូវបានបង្ខំឲ្យទទួលការព្យាបាល វះកាត់ ធ្វើតេស្តសាកល្បង ឬកាត់ផ្តាច់សេវាកម្មព្យាបាល ទាំងផ្នែកចិត្តសាស្ត្រ និងវេជ្ជសាស្ត្រ ក្រោមទម្រង់ផ្សេងៗ ដោយសារតែនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ នោះឡើយ ។ ពោលគឺថា មិនមែនដោយសារតែនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រនោះទេ ដែលប្រើជាសម្អាងក្នុងការទទួលពិនិត្យព្យាបាល និងមិនត្រូវបានពិនិត្យព្យាបាល ការពារ ឬគាបសង្កត់ នោះទេ ។

**រដ្ឋមានកាតព្វកិច្ចត្រូវ ៖**

ក. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាថាមានកិច្ចការពារពេញលេញ ប្រឆាំងនឹងការប្រើប្រាស់ថ្នាំដែលប៉ះពាល់ដល់សុខភាព ដោយផ្អែកលើនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ រាប់ទាំងការផ្អែកលើបុរេនិច្ឆ័យ មិនថាដោយសារតែវប្បធម៌ ឬកត្តាផ្សេងទៀត តាមរយៈការប្រព្រឹត្ត កាយវិការ និងបទដ្ឋានយេនឌ័រដែលយល់ឃើញ

ខ. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាថាគ្មានកុមារណាម្នាក់ត្រូវបានធ្វើឲ្យរូបរាងកាយ មានការប្រែប្រួល ដោយសារការប្រើប្រាស់នីតិវិធីព្យាបាលតាមវេជ្ជសាស្ត្រក្នុងគោលបំណងកំណត់អត្តសញ្ញាណយេនឌ័រ ដោយគ្មានពិគ្រោះយោបល់យល់ព្រម ដោយពេញលេញ ដោយសេរី និងផ្តល់ដំណឹងជាមុន ដល់កុមារទាំងនោះឡើយ ដោយអនុលោមតាមអាយុ និងភាពចាស់ទុំរបស់ក្មេង ហើយនិងគោលការណ៍ដែលមានចែង លើរាល់សកម្មភាពនានាដែលពាក់ព័ន្ធនឹងកុមារ ហើយដែលផលប្រយោជន៍របស់កុមារគួរត្រូវបានគេគិតដល់ជាចម្បង

គ. បង្កើតវិធានការការពារផ្សេងៗដល់កុមារ ដើម្បីធានាថាគ្មានកុមារណាម្នាក់ នឹងត្រូវប្រឈមនឹងហានិភ័យដោយសារការបំពានវេជ្ជសាស្ត្រ

ឃ. ធានាការការពារដល់បុគ្គលគ្រប់រូប ដែលមាននិន្នាភេទ និងអត្តសញ្ញាណយេនឌ័រខុសពីគេ ប្រឆាំងនឹងរាល់ការប្រតិបត្តិ ឬការស្រាវជ្រាវវេជ្ជសាស្ត្រ ដោយគ្មានការស្ម័គ្រចិត្ត ឬគ្មានក្រមសីលធម៌ រួមទាំងការដែលជាប់ទាក់ទងនឹងការបង្ការរោគ ការព្យាបាលជំងឺអេដស៍ ឬជំងឺផ្សេងទៀត

ង. ត្រួតពិនិត្យឡើងវិញ និងកែតម្រូវកម្មវិធីផ្តល់ជំនួយផ្នែកសុខភាពផ្សេងៗ ដោយរួមបញ្ចូលទាំងជំនួយអភិវឌ្ឍន៍ ដែលអាចបង្កើតឬផ្តល់ភាពងាយស្រួល ឬដែលអាចជម្រុញឲ្យមានការបំពាន ដូចមានចែងខាងលើ

ច. ធានាថាការព្យាបាលផ្នែកចិត្តសាស្ត្រ និងផ្នែកវេជ្ជសាស្ត្រ ឬការពិគ្រោះយោបល់ បើទោះជាលាតត្រដាង ឬបង្កប់អត្ថន័យណាមួយក៏ដោយ មិនត្រូវសម្អាងលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រមកដាក់ជាលក្ខខណ្ឌ ក្នុងការព្យាបាល វះកាត់ ឬរារាំងនោះទេ ។

## គោលការណ៍ ១៩ ៖សិទ្ធិសេរីភាពក្នុងការមានមតិ និងការសម្តែងមតិ

មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការមានមតិ និងការសម្តែងមតិ ដោយមិនគិតពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រនោះឡើយ ។ សិទ្ធិនេះត្រូវរាប់បញ្ចូលទាំងសេរីភាពក្នុងការសម្តែងអត្តសញ្ញាណរបស់បុគ្គលម្នាក់ៗ តាមរយៈពាក្យសម្តី ឥរិយាបថ សម្លៀកបំពាក់ អត្តចរិត ជម្រើសនៃការដាក់ឈ្មោះ ឬតាមមធ្យោបាយផ្សេងទៀត ក៏ដូចជាសេរីភាពក្នុងការស្វែងរក ការទទួលបាន និងការចែករំលែកព័ត៌មាន និងគំនិតគ្រប់បែបយ៉ាងដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស និន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ តាមរយៈមធ្យោបាយផ្សេងៗ ដោយគ្មានដែនកំណត់ ។

**រដ្ឋមានកាតព្វកិច្ចត្រូវ ៖**

ក. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាឲ្យទទួលបានដោយពេញលេញ នូវសិទ្ធិសេរីភាពក្នុងការមានមតិ និងការសម្តែងមតិ ទន្ទឹមនឹងការគោរពដល់សិទ្ធិ និងសេរីភាពរបស់អ្នកដ៏ទៃ ដោយគ្មានការរើសអើងលើនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ រួមទាំងការទទួលបាន និងការចែករំលែកព័ត៌មាន និងគំនិតដែលទាក់ទងនឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ក៏ដូចជាការទាក់ទងទៅនឹងការតស៊ូមតិពាក់ព័ន្ធនឹងសិទ្ធិស្របច្បាប់ ការបោះពុម្ពផ្សាយឯកសារ ការផ្សព្វផ្សាយ ការរៀបចំនិងការចូលរួមសន្និសីទ ព្រមទាំងការចែករំលែក និងការទទួលបានព័ត៌មានស្តីអំពីសុវត្ថិភាពផ្លូវភេទ

ខ. ធានាថាលទ្ធផល និងការរៀបចំប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលរដ្ឋមានគោលការណ៍ពហុបែប និងគ្មានការរើសអើងលើបញ្ហានិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ហើយដែលគោលការណ៍ជ្រើសរើស និងតែងតាំងបុគ្គលិកសម្រាប់ស្ថាប័ននេះ មិនរើសអើងលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រនោះឡើយ

គ. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាថា បុគ្គលគ្រប់រូបអាចប្រើប្រាស់សិទ្ធិដោយពេញលេញ ក្នុងការសម្តែងអត្តសញ្ញាណ ឬបុគ្គលភាពរបស់ពួកគេ ដោយរួមបញ្ចូលទាំងតាមរយៈពាក្យសម្តី ឥរិយាបថ សម្លៀកបំពាក់ អត្តចរិត ជម្រើសនៃការដាក់ឈ្មោះ ឬតាមមធ្យោបាយផ្សេងទៀត

ឃ. ធានាថាទស្សនៈនៃរបៀបរៀបរយ ក្រមសីលធម៌ សុខភាព និងសុវត្ថិភាពជាសាធារណៈ មិនត្រូវបានប្រើប្រាស់ដើម្បីរឹតបន្តឹង ក្នុងឥរិយាបទរើសអើងដល់ការប្រើប្រាស់សេរីភាពក្នុងការមានមតិ និងការសម្តែងមតិ ដែលគាំទ្រដល់និន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រដែលមានលក្ខណៈខុសពីគេ

ង. ធានាថាការប្រើប្រាស់សេរីភាពក្នុងការមានមតិ និងការសម្តែងមតិ មិនរំលោភបំពានដល់សិទ្ធិ និងសេរីភាពរបស់បុគ្គលដែលមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រខុសពីគេនោះឡើយ

ច. ធានាថា បុគ្គលទាំងអស់ អាចទទួលបានព័ត៌មាន និងគំនិត ក៏ដូចជាការចូលរួមក្នុងការប្រជុំជាសាធារណៈស្មើៗគ្នា ដោយមិនគិតពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រនោះទេ ។

## គោលការណ៍ ២០ ៖ សិទ្ធិសេរីភាពក្នុងការប្រជុំ ឬក្នុងការចងក្រងគ្នាជាសមាគម ដោយសន្តិវិធី

មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការប្រជុំ ឬក្នុងការចងក្រងគ្នាជាសមាគមដោយសន្តិវិធី ដោយរាប់បញ្ចូលទាំងសិទ្ធិក្នុងការធ្វើបាតុកម្មដោយសន្តិវិធី ដោយមិនគិតពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រនោះទេ ។ បុគ្គលគ្រប់រូបអាចបង្កើត និងត្រូវបានគេទទួលស្គាល់ការចងក្រងគ្នាជាសមាគម ដែលផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ និងសមាគមដែលចែករំលែកព័ត៌មាន ដើម្បីជួយសម្រួលដល់ទំនាក់ទំនង ឬដល់ការគាំទ្រចំពោះសិទ្ធិរបស់បុគ្គលដែលមាននិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រខុសពីគេ ដោយមិនរើសអើង ។

**រដ្ឋមានកាតព្វកិច្ចត្រូវ ៖**

ក. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាបាននូវសិទ្ធិក្នុងការរៀបចំ ការចងក្រងគ្នាជាសមាគម ការប្រជុំគ្នា និងការតស៊ូមតិ ដោយសន្តិវិធី ជុំវិញបញ្ហានិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ព្រមទាំងការទទួលបានការទទួលស្គាល់ស្របច្បាប់ ដល់សមាគម ឬក្រុមទាំងនេះ ដោយគ្មានការរើសអើងលើនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រឡើយ

ខ. ធានាថាទស្សនៈនៃរបៀបរៀបរយ ក្រមសីលធម៌ សុខភាព និងសុវត្ថិភាពសាធារណៈ មិនត្រូវបានប្រើប្រាស់ដើម្បីរឹតបន្តឹង ដល់ការប្រើប្រាស់សិទ្ធិក្នុងការប្រជុំ ឬការចងក្រងគ្នាជាសមាគមដោយសន្តិវិធី ដែលគាំទ្រដល់និន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រដែលមានលក្ខណៈខុសពីគេ

គ. គ្មានកាលៈទេសៈណាដែលអាចរារាំង ដល់ការអនុវត្តសិទ្ធិក្នុងការប្រជុំ ឬការចងក្រងគ្នាជាសមាគមដោយសន្តិវិធី ដែលពាក់ព័ន្ធនឹងនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រនោះឡើយ ហើយត្រូវធានាថា មានកិច្ចការពារជារូបវ័ន្តឲ្យបានគ្រប់គ្រាន់ ប្រឆាំងនឹងអំពើហិង្សា ឬការបៀតបៀនកេរ្តិ៍ខ្មាស់ ដើម្បីអាចឲ្យបុគ្គលម្នាក់ៗប្រើប្រាស់សិទ្ធិរបស់ខ្លួនបាន

ឃ. ផ្តល់កម្មវិធីបណ្តុះបណ្តាល និងការលើកកម្ពស់ការយល់ដឹង ដល់អាជ្ញាធរអនុវត្តច្បាប់ទាំងឡាយ និងមន្ត្រីពាក់ព័ន្ធផ្សេងទៀត ដើម្បីឲ្យពួកគាត់ផ្តល់នូវកិច្ចការពារទាំងនេះ

ង. ធានាថាព័ត៌មានដែលផ្សព្វផ្សាយពីច្បាប់ គ្របដណ្តប់ដល់សមាគម និងក្រុមស្ម័គ្រចិត្ត មិនមែនធ្វើឡើងឲ្យមានឥទ្ធិពលលើការរើសអើងចំពោះសមាគម និងក្រុមផ្សេងៗ ដែលធ្វើការឆ្លើយតបនឹងបញ្ហានិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ឬសមាជិករបស់ពួកគេនោះឡើយ ។

## គោលការណ៍ ២១ ៖ សិទ្ធិសេរីភាពខាងការគិត សតិសម្បជញ្ញៈ និងសាសនា

ជនគ្រប់រូបមានសិទ្ធិសេរីភាពខាងការគិត សតិសម្បជញ្ញៈ និងសាសនា ដោយគ្មានការរើសអើងលើនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រនោះឡើយ ។ សិទ្ធិទាំងនេះ នឹងមិនអាចត្រូវបានដកហូតដោយរដ្ឋ សម្អាងតាមច្បាប់ គោលនយោបាយ ឬការអនុវត្តដែលប្រានចោលកិច្ចការពារស្មើគ្នាពីច្បាប់ ឬការរើសអើងលើនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រនោះទេ ។

**រដ្ឋមានកាតព្វកិច្ចត្រូវ ៖**

ក. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាថាសិទ្ធិរបស់បុគ្គលម្នាក់ៗ ដោយមិនគិតពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រនោះ ត្រូវបានធានា និងអាចប្រើប្រាស់សិទ្ធិក្នុងការប្រកាន់ជំនឿសាសនា ឬមិនមែនសាសនារបស់ខ្លួនម្នាក់ឯង ឬជាមួយអ្នកដទៃ ដោយគ្មានការជ្រៀតជ្រែករំខានពីជំនឿរបស់អ្នកដទៃ និងដោយគ្មានការបង្ខំ ឬការដាក់បន្ទុកឲ្យប្រកាន់ជំនឿណាមួយឡើយ

ខ. ធានានូវសិទ្ធិសម្តែងការគោរពបូជា លើកស្ទួយនូវមតិ ការប្រតិបត្តិ និងជំនឿផ្សេងពីគ្នា ហើយនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ មិនត្រូវបានយកមកសម្អាង ថាជាវិសមិត្តភាពនឹងគោលការណ៍សិទ្ធិមនុស្សនោះឡើយ ។

## គោលការណ៍ ២២ ៖ សិទ្ធិធ្វើដំណើរ

មនុស្សគ្រប់រូបស្ថិតនៅក្រោមច្បាប់នៃរដ្ឋមួយ មានសិទ្ធិទទួលបានសេរីភាពធ្វើដំណើរ និងជ្រើសរើសនិវេសនដ្ឋានក្នុងរដ្ឋមួយ ដោយមិនគិតពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រនោះឡើយ ។ និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ នឹងមិនត្រូវដែលបានលើកយកមកជាសម្អាងក្នុងការកម្រិត ឬរារាំងការធ្វើដំណើរទៅកាន់ ចាកចេញពី ឬក៏ត្រឡប់ចូលប្រទេសណាមួយវិញ រួមទាំងប្រទេសរបស់ខ្លួនផង ។

**រដ្ឋមានកាតព្វកិច្ចត្រូវ ៖**

ក. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានានូវសិទ្ធិសេរីភាពធ្វើដំណើរ និងការជ្រើសរើសនិវេសនដ្ឋានក្នុងរដ្ឋមួយដោយមិនគិតពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រនោះឡើយ ។

## គោលការណ៍ ២៣ ៖ សិទ្ធិស្វែងរកកន្លែងជ្រកកោន

មនុស្សគ្រប់រូបមានសិទ្ធិស្វែងរកកន្លែងជ្រកកោននៅប្រទេសដទៃទៀត ក្នុងករណីមានការធ្វើទុកបុកម្នេញមកលើខ្លួន ដោយរួមទាំងការធ្វើទុកបុកម្នេញដោយសារនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រផងដែរ ។ គ្មានរដ្ឋណាមួយអាចធ្វើការផ្លាស់ប្តូរ បណ្តេញ ឬនិរទេសបុគ្គលណាម្នាក់ទៅកាន់រដ្ឋផ្សេងទៀត ដែលបុគ្គលនោះអាចប្រឈមនឹងការភ័យខ្លាចដែលគេដឹងឮពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប ដែលត្រូវបានប្រព្រឹត្តឡើង ដោយសារពីហេតុផលទាក់ទងនឹងនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រនោះឡើយ ។

**រដ្ឋមានកាតព្វកិច្ចត្រូវ ៖**

ក. ត្រួតពិនិត្យ កែប្រែ និងអនុម័តច្បាប់ដើម្បីធានាថា ការទទួលរងការភ័យខ្លាចពីការរងទុក្ខបុកម្នេញដោយសារតែនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ត្រូវបានទទួលស្គាល់ថា ជាមូលដ្ឋានសម្រាប់ការទទួលស្គាល់ថាជាឋានៈនៃជនភៀសខ្លួន និងសុំសិទ្ធិជ្រកកោន

ខ. ធានាថាគ្មានគោលនយោបាយ ឬការអនុវត្តណាមួយ មានការរើសអើងប្រឆាំងនឹងអ្នកសុំសិទ្ធិជ្រកកោន ដោយសម្អាងទៅលើនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រនោះទេ

គ. ធានាថាគ្មានបុគ្គលណាម្នាក់ ត្រូវបានធ្វើការផ្លាស់ប្តូរ បណ្តេញ និរទេសទៅកាន់ប្រទេសដ៏ទៃទៀត ដែលបុគ្គលនោះអាចប្រឈមនឹងការភ័យខ្លាច ដែលគេដឹងឮពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ដែលត្រូវបានប្រព្រឹត្តឡើងពីហេតុនៃនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រឡើយ ។

## គោលការណ៍ ២៤ ៖ សិទ្ធិក្នុងការកសាងគ្រួសារ

បុគ្គលគ្រប់រូបមានសិទ្ធិក្នុងការកសាងគ្រួសារ ដោយមិនគិតពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ។ គ្រួសារកើតឡើងតាមទម្រង់ផ្សេងៗ ។ គ្មានគ្រួសារណាត្រូវរងការរើសអើង ដោយសារនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័ររបស់សមាជិកគ្រួសាររបស់ពួកគេនោះឡើយ ។

**រដ្ឋមានកាតព្វកិច្ចត្រូវ ៖**

ក. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាថា បុគ្គលគ្រប់រូបទទួលបាននូវសិទ្ធិក្នុងការកសាងគ្រួសារ ដោយរួមទាំងសិទ្ធិក្នុងការដែលអាចទទួលយក ឬជំនួយនៃការបង្កើតកូន (រួមទាំងជំនួយពីអ្នកដទៃក្នុងការផ្តល់មេជីវិត) ដោយគ្មានការរើសអើងលើនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ

ខ. ធានាថាច្បាប់ និងគោលនយោបាយទទួលស្គាល់ភាពចម្រុះបែបនៃគ្រួសារ រួមទាំងគ្រួសារដែលកសាងឡើងដោយខ្លួនឯង ឬតាមរយៈអាពាហ៍ពិពាហ៍ ហើយចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាថា គ្មានគ្រួសារណាមួយនឹងរងការរើសអើង ដោយសារនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រនៃសមាជិកគ្រួសាររបស់ពួកគេ ក្នុងការទទួលបានសុខុមាលភាពសង្គម និងប្រយោជន៍សាធារណៈផ្សេងៗ ការងារ និងអន្តោប្រវេសន៍

គ. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាថា រាល់សកម្មភាព ឬការសម្រេចចិត្តផ្សេងៗ ទាក់ទងនឹងកុមារ មិនថាក្មេងនោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្ថាប័នសុខុមាលភាពសាធារណៈ ឬឯកជន តុលាការ ស្ថាប័ននីតិប្រតិបត្តិ ឬនីតិបញ្ញត្តិនោះទេ ផលប្រយោជន៍របស់កុមារទាំងនេះ ត្រូវតែបានយកចិត្តទុកដាក់ជាចម្បង ហើយធានាថា និន្នាការភេទឬអត្តសញ្ញាណយេនឌ័ររបស់កុមារ ឬសមាជិកគ្រួសារ ឬរបស់មនុស្សដ៏ទៃផ្សេងទៀត មិនត្រូវបានចាត់ទុកថាជាវិសមិត្តភាពក្នុងការទទួលបានផលប្រយោជន៍ទាំងនោះនោះទេ

ឃ. រាល់សកម្មភាព ឬការសម្រេចចិត្តផ្សេងៗ ដែលទាក់ទងនឹងកុមារ ត្រូវធានាថា កុមារដែលមានសមត្ថភាពអាចគិតអំពីទស្សនៈផ្ទាល់ខ្លួនបាន មានសិទ្ធិសម្តែងទស្សនៈខ្លួនឯងដោយសេរី ហើយទស្សនៈទាំងនោះ ត្រូវថ្លឹងថ្លែងនឹងអាយុ និងភាពចាស់ទុំរបស់ក្មេង

ង. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាថារដ្ឋទទួលស្គាល់អាពាហ៍ពិពាហ៍ ឬការចងមេត្រីភាពដែលត្រូវបានចុះបញ្ជី រវាងអ្នកដែលស្រឡាញ់ភេទដូចគ្នា ការអនុញ្ញាត

អាទិភាព កាតព្វកិច្ច ឬផលប្រយោជន៍ទាំងឡាយណា ដែលអ្នកមានចំណងអាពាហ៍ពិពាហ៍ ឬដៃគូរដែលបានចុះបញ្ជីរវាងអ្នកដែលមានភេទដូចគ្នា អាចទទួលបាននោះ ក៏អាចទទួលបានដោយស្មើៗគ្នាសម្រាប់អ្នកដែលមានចំណងអាពាហ៍ពិពាហ៍ ឬដៃគូរដែលចុះបញ្ជី ដែលមានភេទដូចគ្នាផងដែរ

ច. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាថាកាតព្វកិច្ច ការអនុញ្ញាត អាទិភាព ឬផលប្រយោជន៍ទាំងឡាយណា ដែលដៃគូរមិនបានរៀបអាពាហ៍ពិពាហ៍ ហើយមានភេទខុសគ្នា អាចទទួលបាននោះ ក៏អាចទទួលបានដោយស្មើៗគ្នា សម្រាប់ដៃគូរមិនបានរៀបអាពាហ៍ពិពាហ៍ ហើយមានភេទដូចគ្នាផងដែរ

ឆ. ធានាថាអាពាហ៍ពិពាហ៍ និងចំណងមេត្រីភាពដែលត្រូវបានទទួលស្គាល់ដោយស្របច្បាប់ នឹងអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការព្រមព្រៀងដោយសេរី និងពេញលេញពីអនាគតប្តីប្រពន្ធ ឬដៃគូរ ។

## គោលការណ៍ ២៥ ៖ សិទ្ធិចូលរួមក្នុងជីវភាពសាធារណៈ

ប្រជាពលរដ្ឋគ្រប់រូប មានសិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈ រួមទាំងសិទ្ធិឈរឈ្មោះជាតំណាងរាស្ត្រ ដើម្បីចូលរួមតាក់តែងគោលនយោបាយ ដែលប៉ះពាល់ដល់សុខុមាលភាពរបស់ពួកគេ និងដើម្បីទទួលបានស្មើៗគ្នានូវសេវាសាធារណៈ និងការងារក្នុងមុខងារសាធារណៈ នៅគ្រប់កម្រិតទាំងអស់ រួមទាំងបម្រើសេវាផ្នែកប៉ូលីស និងយោធាដោយគ្មានការរើសអើងពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ។

**រដ្ឋមានកាតព្វកិច្ចត្រូវ ៖**

ក. ត្រួតពិនិត្យឡើងវិញ កែប្រែ និងអនុម័តច្បាប់ ដើម្បីធានាថាបុគ្គលម្នាក់ៗអាចទទួលបានសិទ្ធិពេញលេញ ក្នុងការចូលរួមក្នុងជីវភាពសាធារណៈ និងនយោបាយ រួមទាំងសេវាកម្មរដ្ឋាភិបាល និងការងារនៅក្នុងមុខងារសាធារណៈគ្រប់កម្រិតទាំងអស់ ទាំងសេវាកម្មផ្នែកប៉ូលីស និងយោធា ដោយមិនរើសអើង ហើយត្រូវបានគោរពទាំងស្រុងលើនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ

ខ. ចាត់វិធានការសមស្រប ដើម្បីលុបបំបាត់ការវាយតម្លៃខុស និងគំនិតបុរេនិច្ឆ័យ ទៅលើនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ដែលរារាំង និងរឹតត្បិតដល់ការចូលរួមក្នុងជីវភាពសាធារណៈ

គ. ធានាថាបុគ្គលម្នាក់ៗ មានសិទ្ធិចូលរួមក្នុងការតាក់តែងគោលនយោបាយ ដែលមានឥទ្ធិពលលើសុខុមាលភាពរបស់ពួកគេ ដោយមិនរើសអើង និងត្រូវបានគោរពនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ។

## គោលការណ៍ ២៦ ៖ សិទ្ធិចូលរួមក្នុងជីវភាពវប្បធម៌

បុគ្គលគ្រប់រូបមានសិទ្ធិចូលរួមដោយសេរីក្នុងជីវភាពវប្បធម៌ ដោយមិនគិតពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រនោះទេ ហើយសិទ្ធិក្នុងការសម្តែងអំពីភាពចម្រុះបែបនៃនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ តាមរយៈការចូលរួមក្នុងជីវភាពវប្បធម៌នេះ ត្រូវបានធានា ។

**រដ្ឋមានកាតព្វកិច្ចត្រូវ ៖**

ក. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាបាននូវឱកាសសម្រាប់មនុស្សគ្រប់គ្នា ឲ្យអាចចូលរួមក្នុងជីវភាពវប្បធម៌ ដោយការគោរពនិងមិនគិតពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ

ខ. ជួយជំរុញការជជែកនានា និងការគោរពគ្នាទៅវិញទៅមក ក្នុងចំណោមអ្នកប្រឆាំងលើក្រុមវប្បធម៌ផ្សេងៗគ្នា ដែលមាននៅក្នុងរដ្ឋ រួមទាំងក្រុមដែលមានទស្សនៈខុសគ្នា លើនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ ឲ្យមានការគោរពសិទ្ធិមនុស្សដូចមានចែងក្នុងគោលការណ៍ទាំងនេះ ។

## គោលការណ៍ ២៧ ៖ សិទ្ធិក្នុងការលើកកម្ពស់សិទ្ធិមនុស្ស

បុគ្គលគ្រប់រូបមានសិទ្ធិលើកកម្ពស់កិច្ចការពារ និងស្វែងយល់ពីសិទ្ធិមនុស្ស នៅកម្រិតថ្នាក់ជាតិនិងអន្តជាតិ ដោយលក្ខណៈបុគ្គល និងចូលរួមជាមួយអ្នកដទៃក្នុងសហគមន៍ ដោយមិនរើសអើងពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រនោះឡើយ ។ សិទ្ធិនេះរួមមានសកម្មភាពផ្ទាល់ ក្នុងការលើកកម្ពស់ និងកិច្ចការពារសិទ្ធិមនុស្សរបស់អ្នកដែលមាននិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រផ្សេងគ្នា ក៏ដូចជាសិទ្ធិក្នុងការបង្កើត និងការពិភាក្សាអំពីច្បាប់សិទ្ធិមនុស្សថ្មីៗ និងសិទ្ធិក្នុងការធ្វើការតស៊ូមតិឲ្យមានការទទួលយល់ព្រម ។

**រដ្ឋមានកាតព្វកិច្ចត្រូវ ៖**

ក. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាឲ្យបាននូវមជ្ឈដ្ឋានមួយដែលអនុគ្រោះដល់សកម្មភាពទាំងឡាយ ឆ្ពោះទៅកាន់ការលើកកម្ពស់ ការការពារ និងការស្វែងយល់អំពីសិទ្ធិមនុស្ស រួមទាំងសិទ្ធិដែលពាក់ពន្ធ័នឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រផង

ខ. ចាត់វិធានការសមស្របផ្សេងៗ ដើម្បីប្រឆាំងនឹងសកម្មភាព ឬយុទ្ធនាការដៅមុខសញ្ញាដល់អ្នកការពារសិទ្ធិមនុស្សទាំងអស់ ដែលធ្វើការលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ក៏ដូចជាដល់អ្នកការពារសិទ្ធិមនុស្សដែលមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រផ្សេងទៀតដែរ

គ. ធានាថាអ្នកការពារសិទ្ធិមនុស្ស អាចចូលរួម និងធ្វើការទំនាក់ទំនងជាមួយអង្គការ ស្ថាប័នជាតិនិងអន្តរជាតិ ដោយមិនរងការរើសអើងដោយសារនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ និងដោយសារបញ្ហាសិទ្ធិមនុស្សណាមួយ ដែលពួកគាត់ធ្វើការតស៊ូមតិនោះឡើយ

ឃ. ធានាឲ្យបាននូវកិច្ចការពារចំពោះអ្នកការពារសិទ្ធិមនុស្ស ដែលធ្វើការងារពាក់ព័ន្ធនឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ប្រឆាំងរាល់ទម្រង់អំពើហិង្សា ការគំរាមកំហែង ការតបត ការរើសអើងក្នុងសង្គមឬតាមលក្ខណៈច្បាប់ ការគាបសង្កត់ ឬសកម្មភាពបំពានផ្សេងៗប្រព្រឹត្តិដោយរដ្ឋ ឬតួអង្គមិនមែនរដ្ឋ ក្នុងការឆ្លើយតបនឹងសកម្មភាពសិទ្ធិមនុស្សរបស់ពួកគាត់ ។ ការការពារដូចគ្នាដែរ គួរតែធានាឲ្យបានចំពោះអ្នកការពារសិទ្ធិមនុស្ស ដែលធ្វើការពាក់ពន្ធ័នឹងបញ្ហាផ្សេងៗ ប្រឆាំងនឹងការប្រព្រឹត្តមកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់ពួកគាត់ ដូចរៀបរាប់ខាងលើ

ង. គាំទ្រដល់ការទទួលស្គាល់ និងការជឿជាក់លើអង្គការទាំងឡាយដែលជួយលើកកម្ពស់ និងការពារសិទ្ធិមនុស្សចំពោះអ្នកដែលមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រចម្រុះបែប ទាំងនៅថ្នាក់ជាតិ និងអន្តរជាតិ ។

## គោលការណ៍ ២៨ ៖ សិទ្ធិទទួលបានមធ្យោបាយដោះស្រាយ និងសំណងដែលមានប្រសិទ្ធភាព

ជនរងគ្រោះ ពីការរំលោភបំពានសិទ្ធិមនុស្សគ្រប់រូប រួមទាំងការរំលោភបំពាន ដោយសារនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រនោះ មានសិទ្ធិទទួលបានមធ្យោបាយដោះស្រាយ និងសំណងដែលមានប្រសិទ្ធិភាព គ្រប់គ្រាន់ និងសមស្រប។ រាល់វិធានការដែលបានដាក់ចេញ ដើម្បីផ្តល់ជាមធ្យោបាយដោះស្រាយទាំងនេះ ឬដើម្បីធានានូវការរីកចម្រើនគ្រប់គ្រាន់របស់បុគ្គលដែលមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រចម្រុះនោះ គឺមានសារៈសំខាន់ដល់ សិទ្ធិទទួលបានមធ្យោបាយដោះស្រាយ និងសំណងដែលមាន ប្រសិទ្ធិភាព ។

**រដ្ឋមានកាតព្វកិច្ចត្រូវ ៖**

ក. បង្កើតនីតិវិធីស្របច្បាប់ចាំបាច់ផ្សេងៗ រួមទាំងឆ្លងកាត់ការត្រួតពិនិត្យច្បាប់ និងគោលនយោបាយឡើងវិញ ដើម្បីធានាថា ជនរងគ្រោះពីការរំលោភបំពានសិទ្ធិមនុស្ស ពីហេតុនៃនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ទទួលបានការសងជំងឺចិត្តពេញលេញ តាមរយៈការផ្តល់ជាសំណងចំពោះអ្វីដែលបាត់បង់ ការប៉ះប៉ូវ ការទូទាត់ធ្វើឲ្យប្រសើរឡើងវិញ ការធានារ៉ាប់រងមិនមានការសងសឹក និងដំណោះស្រាយតាមមធ្យោបាយផ្សេងៗទៀត

ខ. ធានាថាមធ្យោបាយដំណោះស្រាយសងជំងឺចិត្ត ត្រូវបានអនុលោមតាម និងអនុវត្តទាន់ពេលវេលាកំណត់

គ. ធានាឲ្យបាននូវស្ថាប័ន និងស្តង់ដារដែលមានប្រសិទ្ធភាព ក្នុងការផ្តល់មធ្យោបាយដោះស្រាយ និងសំណង ហើយធានាថាបុគ្គលិកនៃស្ថាប័នទាំងនេះ ត្រូវបានបណ្តុះបណ្តាលអំពីបញ្ហារំលោភបំពានសិទ្ធិមនុស្ស ដោយសារមូលដ្ឋាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ

ឃ. ធានាថាបុគ្គលម្នាក់ៗ បានទទួលព័ត៌មានចាំបាច់ផ្សេងៗ អំពីនីតិវិធីក្នុងការស្វែងរកមធ្យោបាយដោះស្រាយ និងសំណងនានា

ង. ធានាថាជំនួយផ្នែកហិរញ្ញវត្ថុ ត្រូវផ្តល់ដល់អ្នកដែលគ្មានសមត្ថភាពចំណាយ លើការទាមទារសំណង ហើយរាល់ឧបសគ្គក្នុងការទាមទារសំណងជាលក្ខណៈហិរញ្ញវត្ថុ ឬលក្ខណៈផ្សេងទៀត ត្រូវបានលុបចេញ

ច. ធានាឲ្យមានកម្មវិធីបណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹង ដោយរួមបញ្ចូលទាំងវិធានការនានាសំដៅលើគ្រូបង្រៀន និងសិស្សានុសិស្ស នៅគ្រប់កម្រិតស្ថាប័នអប់រំសាធារណៈ ស្ថាប័នការងារ និងជនប្រព្រឹត្តិអំពើបំពានសិទ្ធិមនុស្សទាំងអស់ ធ្វើយ៉ាងណាដើម្បីជំរុញការគោរព និយាមស្តង់ដារសិទ្ធិមនុស្ស ដែលមានចែងក្នុងគោលការណ៍នេះ ព្រមទាំងដើម្បីប្រឆាំងនឹងឥរិយាបទរើសអើង ដែលឈរលើមូលដ្ឋាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ។

## គោលការណ៍ ២៩ ៖ ទំនួលខុសត្រូវ

ជនគ្រប់រូបដែលត្រូវបានប្រឈមនឹងការបំពានសិទ្ធិ រួមទាំងសិទ្ធិនានា ដែលបានចែងក្នុងគោលការណ៍នេះ មានសិទ្ធិឲ្យជនដែលប្រព្រឹត្តការបំពានទាំងនេះ ដោយផ្ទាល់ឬដោយប្រយោល មិនថាជននោះ ជាឬមិនមែនជាមន្ត្រីរាជការក៏ដោយ ត្រូវទទួលខុសត្រូវលើទង្វើរបស់ពួកគេ ឲ្យសាកសមនឹងកម្រិតនៃទោសកំហុស ។ គ្មានការលើកលែងទោសដល់ឧក្រិដ្ឋជន នៃការរំលោភបំពានសិទ្ធិមនុស្ស ដែលជាប់ទាក់ទងនឹងនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រនោះទេ ។

**រដ្ឋមានកាតព្វកិច្ចត្រូវ ៖**

ក. បង្កើតនីតិវិធីព្រហ្មទណ្ឌ ស៊ីវិល រដ្ឋបាល និងនីតិវិធីសមស្រប ដែលអាចទាក់ទងបាន និងដែលមានប្រសិទ្ធភាព ក៏ដូចជាយន្តការត្រួតពិនិត្យផ្សេងទៀត ដើម្បីធានាថា ជនប្រព្រឹត្តិល្មើសនឹងទទួលខុសត្រូវចំពោះការបំពានសិទ្ធិមនុស្សទាំងឡាយ ដែលពាក់ព័ន្ធនឹងនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ

ខ. ធានាថា រាល់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយសារនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័ររបស់ជនរងគ្រោះ រួមទាំងបទឧក្រិដ្ឋកម្មផ្សេងៗ ដែលរៀបរាប់ក្នុងគោលការណ៍នេះ ត្រូវបានស៊ើបអង្កេតបានត្រឹមត្រូវ និងច្បាស់លាស់ ហើយក្នុងករណីដែលមានភ័ស្តុតាងច្បាស់លាស់ត្រូវបានរកឃើញ នោះជនល្មើសត្រូវបានកាត់ទោស ជំនុំជម្រះ និងដាក់ទណ្ឌកម្មទៅតាមការកំណត់ទុក

គ. បង្កើតស្ថាប័នឯករាជ្យ និងប្រកបដោយប្រសិទ្ធភាព និងនីតិវិធីដើម្បីត្រួតពិនិត្យផែនការ និងការពង្រឹងច្បាប់ និងគោលនយោបាយផ្សេងៗ សំដៅលុបបំបាត់ការរើសអើងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ

ឃ. លុបបំបាត់ឧបសគ្គផ្សេងៗ ដែលរារាំងជនល្មើសពីការទទួលខុសត្រូវ លើអំពើរំលោភបំពានសិទ្ធិមនុស្សដោយសារនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ។

## អនុសាសន៍បន្ថែម

មនុស្សគ្រប់រូបក្នុងសង្គម និងសហគមន៍អន្តរជាតិទាំងអស់ ត្រូវមានទំនួលខុសត្រូវចំពោះការយល់ដឹងអំពីសិទ្ធិមនុស្ស ។ អាស្រ័យហេតុនេះ យើងសូមលើកអនុសាសន៍ដូចតទៅ ៖

ក. ឧត្តមស្នងការ អង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស (ឧត្តមស្នងការ) គាំទ្រគោលការណ៍ទាំងនេះ ជំរុញការអនុវត្តគោលការណ៍នេះឲ្យបានទូលំទូលាយពេញពិភពលោក ហើយបញ្ចូលគោលការណ៍ទាំងនេះ ទៅក្នុងការងាររបស់ឧត្តមស្នងការ រួមទាំងគ្រប់កម្រិតការងារទាំងអស់

ខ. ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ គាំទ្រគោលការណ៍ទាំងនេះ ហើយនិងផ្តល់ការពិនិត្យពិច័យជាសំខាន់ លើបញ្ហារំលោភបំពានសិទ្ធិមនុស្ស ដោយសារនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ព្រមទាំងផ្តោតលើការជំរុញឲ្យរដ្ឋភាគី អនុលោមតាមគោលការណ៍នេះ

គ. នីតិក្រមពិសេសរបស់អង្គការសហប្រជាជាតិ យកចិត្តទុកដាក់ឲ្យបានខ្លាំងក្លា ចំពោះការរំលោភបំពានសិទ្ធិមនុស្ស ដោយសារនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ និងធ្វើសមាហរណកម្មគោលការណ៍ទាំងនោះ ទៅក្នុងការអនុវត្តនៅក្នុងអាណត្តិរៀងៗខ្លួនរបស់ពួកគេ

ឃ. ដោយយោងទៅតាមសេចក្តីសម្រេចឆ្នាំ១៩៩៦/៣១ ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច ត្រូវតែទទួលស្គាល់ និងផ្តល់អំណាចដល់អង្គការក្រៅរដ្ឋាភិបាលទាំងឡាយ ដែលមានបំណងលើកកម្ពស់ និងការពារសិទ្ធិមនុស្សចំពោះអ្នកដែលនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រខុសពីគេ

ង. ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិទាំងអស់ ត្រូវធ្វើសមាហរណកម្មគោលការណ៍ទាំងនេះ នៅក្នុងការប្រតិបត្តិតាមអាណត្តិរៀងៗខ្លួនរបស់ពួកគេ រួមទាំងចងក្រងករណីច្បាប់ និងត្រួតពិនិត្យរបាយការណ៍របស់រដ្ឋ ហើយក្នុងករណីដែលចាំបាច់ ត្រូវដាក់ចេញនូវសេចក្តីអធិប្បាយទូទៅ ឬអត្ថបទបកស្រាយលើបទដ្ឋានច្បាប់សិទ្ធិមនុស្ស ដែលត្រូវអនុវត្តដល់អ្នកដែលមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រចម្រុះបែប

ច. អង្គការសុខភាពពិភពលោក និងអាជ្ញាធរប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ ត្រូវចងក្រងសេចក្តីណែនាំអំពីការផ្តល់សេវាកម្ម និងការថែទាំសុខភាព ដើម្បីឆ្លើយតបនឹងតម្រូវការរបស់បុគ្គលដែលមានពាក់ព័ន្ធនឹងនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ដោយការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ពួកគេឲ្យបានពេញលេញ

ឆ. ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ត្រូវធ្វើសមាហរណកម្មគោលការណ៍ទាំងនេះ សំដៅការពារអ្នកដែលមានបទពិសោធន៍ ឬរងការភ័យខ្លាច ពីការកាត់ទោស ដោយសារមូលដ្ឋាននិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ហើយត្រូវធានាថា គ្មានបុគ្គលណាម្នាក់នឹងត្រូវទទួលរងការរើសអើងក្នុងការទទួលបាននូវជំនួយមនុស្សធម៌ ឬសេវាកម្មផ្សេងទៀត ឬការកំណត់ឋានៈជនភៀសខ្លួន ដោយសារតែមូលដ្ឋាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រនោះឡើយ

ជ. អង្គការអន្តររដ្ឋាភិបាលប្រចាំតំបន់ និងអនុតំបន់ ដែលមានការប្តេជ្ញាចំពោះសិទ្ធិមនុស្ស ក៏ដូចជាសិទ្ធិសញ្ញាស្តីអំពីសិទ្ធិមនុស្សប្រចាំតំបន់ ត្រូវធានាថាការលើកស្ទួយគោលការណ៍នេះ មានសារៈសំខាន់បំផុត ដល់ការប្រតិបត្តិយន្តការសិទ្ធិមនុស្ស នីតិវិធីនិងផែនការផ្សេងៗ និងគំនិតផ្តួចផ្តើមនានា

ឈ. តុលាការសិទ្ធិមនុស្សប្រចាំតំបន់ ត្រូវធ្វើសមាហរណកម្មគោលការណ៍ ដែលមានការជាប់ទាក់ទងនឹងសន្ធិសញ្ញាសិទ្ធិមនុស្ស ដែលគេបានបកស្រាយនៅក្នុងករណីច្បាប់ស្ដីពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ

ញ. អង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការពាក់ពន្ធ័នឹងសិទ្ធិមនុស្ស នៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ត្រូវលើកកម្ពស់ការគោរពគោលការណ៍នេះ ដោយអនុវត្តគម្រោងផែនការ ក្នុងអាណត្តិរៀងៗខ្លួនរបស់ពួកគេ

ដ. អង្គការមនុស្សធម៌ ត្រូវដាក់បញ្ចូលនូវគោលការណ៍ទាំងនេះ ទៅក្នុងប្រតិបត្តិការមនុស្សធម៌ ឬប្រតិបត្តិការសង្គ្រោះ និងទប់ស្កាត់ការរើសអើងប្រឆាំងនឹងអ្នកមាននិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ក្នុងការទទួលបានជំនួយ និងសេវាកម្មផ្សេងៗ

ឋ. ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ ត្រូវលើកកម្ពស់ការគោរពគោលការណ៍ទាំងនេះ ពីសំណាក់រដ្ឋ និងតួអង្គមិនមែនរដ្ឋ ហើយដាក់បញ្ចូលគោលការណ៍នេះទៅក្នុងការងាររបស់ពួកគេ លើការលើកស្ទួយ ឬការការពារសិទ្ធិមនុស្ស ចំពោះអ្នកដែលមាននិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រខុសពីគេ

ឌ. ស្ថាប័នវិជ្ជាជីវៈ រួមទាំងស្ថាប័នសុខាភិបាល ស្ថាប័នឧក្រិដ្ឋកម្ម ឬតុលាការស៊ីវិល និងស្ថាប័នអប់រំនានា ត្រូវត្រួតពិនិត្យការអនុវត្ត និងការណែនាំដើម្បីធានាថាពួកគេ បានលើកកម្ពស់យ៉ាងខ្លាំងក្លា ក្នុងការប្រតិបត្តិគោលការណ៍ទាំងនេះ

ឍ. ស្ថាប័នពាណិជ្ជកម្មត្រូវតែទទួលស្គាល់ និងធ្វើសកម្មភាពដោយយោងទៅតាមតួនាទីសំខាន់ ដែលពួកគេត្រូវធានា ដល់ការគោរពគោលការណ៍ទាំងនេះ នៅកន្លែងធ្វើការផ្ទាល់របស់ពួកគេ និងលើកកម្ពស់គោលការណ៍ទាំងនោះ ទាំងក្នុងថ្នាក់ជាតិ និងអន្តរជាតិ

ណ. ប្រពន្ធ័ផ្សព្វផ្សាយ ត្រូវជៀសវាងការប្រើប្រាស់គំនិតបុរេនិច្ច័យដែលទាក់ទងនឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ព្រមទាំងលើកកម្ពស់ការយោគយល់អត់អោន និងទទួលស្គាល់នូវភាពចម្រុះបែបនៃនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ព្រមទាំងលើកកម្ពស់ការយល់ដឹងជុំវិញបញ្ហាទាំងនេះ

ត. ម្ចាស់ជំនួយមកពីរដ្ឋាភិបាល និងឯកជន ត្រូវផ្ដល់ជំនួយផ្នែកហិរញ្ញវត្ថុ ដល់អង្គការក្រៅរដ្ឋាភិបាល និងអង្គការផ្សេងៗ ដើម្បីលើកកម្ពស់និងការពារសិទ្ធិមនុស្ស ដល់ជនដែលមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រខុសគេ ។

**គោលការណ៍ និងអនុសាសន៍**ទាំងនេះ ឆ្លុះបញ្ចាំងនូវការអនុវត្តច្បាប់អន្តរជាតិ ស្ដីអំពីសិទ្ធិមនុស្ស ឲ្យមានប្រសិទ្ធភាពដល់ជីវភាព និងបទពិសោធន៍របស់ជនគ្រប់រូប ដែលមាននិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រចម្រុះបែប ហើយមិនមានចំណុចណាមួយនៃគោលការណ៍នេះ ត្រូវបានបកស្រាយ ក្នុងន័យរឹតបន្តឹង ឬកម្រិតដល់សិទ្ធិ និងសេរីភាពរបស់ជនទាំងនេះ ដែលបានទទួលស្គាល់ដោយច្បាប់ ឬស្តង់ដារថ្នាក់អន្តរជាតិ ថ្នាក់តំបន់ ឬថ្នាក់ជាតិ នោះឡើយ ៕

## ឧបសម្ព័ន្ធ

# ហត្ថលេខីនៃគោលការណ៍យ៉ូកយ៉ាកាតា ៖

Philip Alston (អូស្ត្រាលី) ជាអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីតុលាការវិសមញ្ញ ការកាត់ទោសសង្ខេប និងតាមអំពើចិត្ត និងជាសាស្ត្រាចារ្យផ្នែកច្បាប់ នៅសាកលវិទ្យាល័យច្បាប់នៃទីក្រុងញ៉ូយ៉កនៃសហរដ្ឋអាមេរិក ។

Maxim Anmeghichean (ម៉ូដូវ៉ា) មកពីសមាគមអន្តរជាតិក្រុមស្រឡាញ់ភេទដូចគ្នានៅតំបន់សហភាពអឺរ៉ុប ។

Mauro Cabral (**អាហ្សង់ទីន**) ជាអ្នកស្រាវជ្រាវនៃ Universidad Nacional de Cordoba របស់ប្រទេស**អាហ្សង់ទីន** និងគណៈកម្មការសិទ្ធិមនុស្សអន្តរជាតិស្តីពីក្រុមស្រលាញ់ភេទដូចគ្នា ។

Edwin Cameron (អាព្រិចខាងត្បូង) មកពីតុលាការយុត្តិធម៌កំពូលនៃ**សាលា**ឧទ្ធរណ៍ នៅ Bloemfontein អាព្រិចខាងត្បូង ។

Sonia Onufer Correa (ប្រេ**ហ្ស៊ី**ល) ជំនួយ**ការ**ស្រាវជ្រាវ នៃសមាគមចំណេះដឹងអំពីបញ្ហាអេដ**ស៍**របស់ប្រជាពលរដ្ឋប្រេ**ហ្ស៊ីល** និងជាសហប្រធាននៃក្រុមឃ្លាំមើលគោលនយោបាយផ្លូវភេទ (សហប្រធានកិច្ចប្រជុំអ្នកឯកទេស) ។

Yakin Erturk (ទួគី) អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីអំពើហិង្សាប្រឆាំងលើស្ត្រី និងជាសាស្ត្រាចារ្យនៃនាយកដ្ឋានសង្គមវិទ្យា នៅសាកលវិទ្យាល័យបច្ចេកទេស**មជ្ឈឹម**បូព៌ា នៃទីក្រុងអានការ៉ា ប្រទេសទួគី ។

Elizabeth Evatt (អូស្ត្រាលី) អតីតសមាជិក និងប្រធានគណៈកម្មការអង្គការសហប្រជាជាតិលើការលុបបំបាត់ការរើសអើងប្រឆាំងស្ត្រី និងអតីតសមាជិកនៃគណៈកម្មការសិទ្ធិមនុស្ស នៃអង្គការសហប្រជាជាតិ និងប្រធានគណៈកម្មាការចៅក្រមអន្តរជាតិ ។

Paul Hunt (**ណូវែលហ្សេឡង់**) អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិទទួលបានស្តង់ដារសុខភាព តាមដែលអាចទទួលបានខ្ពស់បំផុត និងជាសាស្ត្រាចារ្យនៃនាយកដ្ឋានច្បាប់ នៅសាកលវិទ្យាល័យ Essex ចក្រភពអង់គ្លេស ។

Asma Jahangir (ប៉ាគីស្ថាន) ជាប្រធានគណៈកម្មកាសិទ្ធិមនុស្សនៃប្រទេសប៉ាគីស្ថាន ។

Maina Kiai (**កេន**យ៉ា) ជាប្រធានគណៈកម្មការជាតិស្តីអំពីសិទ្ធិមនុស្សនៃប្រទេស**កេន**យ៉ា ។

Miloon Kothari (ឥណ្ឌា) អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិទទួលបានលំនៅដ្ឋានគ្រប់គ្រាន់ ។

Judith Mesquita (ចក្រភពអង់គ្លេស) មន្ត្រីស្រាវជ្រាវជាន់ខ្ពស់នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សនៃសាកលវិទ្យាល័យ Essex នៃចក្រភពអង់គ្លេស ។

**Alice M. Miller** (សហរដ្ឋអាមេរិក) ជំនួយការសាស្ត្រាចារ្យ នៃសាលាសុខភាពសាធារណៈ និងសហនាយកកម្មវិធីសិទ្ធិមនុស្សនៃសាកលវិទ្យាល័យ Columbia សហរដ្ឋអាមេរិក ។

**Sanji Mmasenono Monageng** (បូស្វាតណា) ចៅក្រមនៃតុលាការជាន់ខ្ពស់ (សាធារណរដ្ឋហ្គាមបៀរ) និងប្រធានគណៈកម្មការអាព្រិចស្តីអំពីមនុស្ស និងសិទ្ធិពលរដ្ឋ និងប្រធានគណៈកម្មការឃ្លាំមើលប្រតិបត្តិការគោលការណ៍កោះ Robben ស្តីពីការហាមឃាត់ និងការរារាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (គណៈកម្មការអាព្រិចស្តីអំពីសិទ្ធិមនុស្ស) ។

**Vitit Muntarbhorn** (ថៃ) អ្នករាយការណ៍ពិសេសរបស់អង្គការសប្រជាជាតិ ស្តីអំពីស្ថានភាពសិទ្ធិមនុស្ស ប្រចាំសារធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េ និងជាសាស្ត្រាចារ្យច្បាប់នៅសាកលវិទ្យាល័យ Chulalongkorn ប្រទេសថៃ(សហប្រធាននៃកិច្ចប្រជុំអ្នកឯកទេស) ។

**Lawrence Mute** (កេនយ៉ា) ប្រធានគណៈកម្មការជាតិសិទ្ធិមនុស្សនៃប្រទេសកេនយ៉ា ។

**Manfred Nowak** (អូទ្រីស) អ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិស្តីការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប និងជាសមាជិកគណៈកម្មការចៅក្រមអន្តរជាតិ និងជាសាស្ត្រាចារ្យសិទ្ធិមនុស្សនៃសាកលវិទ្យាល័យ Vienna នៅអូទ្រីស និងជានាយកនៃវិទ្យាស្ថានសិទ្ធិមនុស្សនៃ Ludwig Boltzmann ។

**Ana Elena Obando Mendoza** (គូស្តារីកា) ជាមេធាវីស្រី សកម្មជនសិទ្ធិស្ត្រី និងជាទីប្រឹក្សាអន្តរជាតិ ។

**Michael O′ Flaherty** (អៀរឡង់) សមាជិកគណៈកម្មការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ និងជាសាស្ត្រចារ្យនៃការអនុវត្តសិទ្ធិមនុស្ស និងសហនាយកនៃមជ្ឈមណ្ឌលច្បាប់សិទ្ធិមនុស្ស នៅសាកលវិទ្យាល័យ Nottingham នៃចក្រភពអង់គ្លេស (អ្នករាយការណ៍ពិសេសសម្រាប់ការអភិវឌ្ឍគោលការណ៍ Yogyakarta) ។

**Sunil Pant** (នេប៉ាល់) ប្រធានសហគមន៍មរកតនៃប្រទេសនេប៉ាល់ ។

**Dimitrina Petrova** (ប៊ុលហ្គារី) នាយកប្រតិបត្តិនៃជំនឿនៃសិទ្ធិស្មើគ្នា ។

**Rudi Mohammed Rizki** (ឥណ្ឌូនេស៊ី) អ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិស្តីពីសាមគ្គីភាពអន្តរជាតិ និងជាសាស្ត្រាចារ្យជាន់ខ្ពស់ ព្រមទាំងជាព្រឹទ្ធបុរសរងនៃកិច្ចការអប់រំនៃនាយកដ្ឋានច្បាប់ នៃសាកលវិទ្យាល័យ Padjadjaran ប្រទេសឥណ្ឌូនេសី ។

**Mary Robinson** (អៀរឡង់) ស្ថាបនិកនៃការយល់ដឹងពីសិទ្ធិមនុស្ស ៖ គំនិតផ្តួចផ្តើមនៃសាកលភាវូនីយកម្មក្រមសីលធម៌ និងជាអតីតប្រធានាធិបតីនៃប្រទេសអៀរឡង់ និងជាអតីតប្រធានទីស្នងការជាន់ខ្ពស់នៃសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ។

**Nevena Vuckovic Sahovic** (សៀរប៊ី) សមាជិកគណៈកម្មការនៃអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ និងជាប្រធាននៃមជ្ឈមណ្ឌលសិទ្ធិកុមារនៃរដ្ឋ Belgrade នៃប្រទេសស៊ីបៀ ។

**Martin scheinin** (ហ្វាំងឡង់) អ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិស្តីអំពីសិទ្ធិ មនុស្ស និងការប្រឆាំងអំពើភេរវកម្ម និងជាសាស្ត្រាចារ្យច្បាប់អន្តរជាតិ និងច្បាប់រដ្ឋធម្មនុញ្ញ និងជានាយកនៃស្ថាប័នសិទ្ធិមនុស្ស នៃសាកលវិទ្យាល័យ Abo Akademi  នៅប្រទេស**ហ្វាំង**ឡង់ ។

**Wan Yanhai** (ចិន) ស្ថាបនិកគម្រោងផែនការសកម្មភាព AI ZHI និងជាប្រធាននៃវិទ្យាស្ថានអប់រំសុខភាពនៃ ទីក្រុងប៉េកាំង AI ZHIXING ។

**Stephen Whittle** (ចក្រភពអង់គ្លេស) សាស្ត្រាចារ្យផ្នែកសមភាពច្បាប់ នៅសាកលវិទ្យាល័យ Manchester Metropolitan នៃចក្រភពអង់គ្លេស ។

**Roman Wieruszewski** (ប៉ូឡូញ) សមាជិកគណៈកម្មការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ និងជាប្រធាននៃមជ្ឈមណ្ឌលសទ្ធិមនុស្សប៉ូសណាន នៅប្រទេសប៉ូឡូញ ។

**Robert Wintemute** (កាណាដា និងចក្រភពអង់គ្លេស) សាស្ត្រាចារ្យនៃច្បាប់សិទ្ធិមនុស្ស មហាវិទ្យាល័យច្បាប់ សាកលវិទ្យាល័យ King's College London នៃចក្រភពអង់គ្លេស ។